# ហេតុអ្វីយើងគប្បីប្រតិបត្តិ
## តាមព្រះពុទ្ធសាសនា



និពន្ធដោយ
ព្រះតេជគុណបណ្ឌិត ក. ស្រីធម្មានន្ទ

ព.ស. ២៥៥៥

# ហេតុអ្វីយើងគប្បីប្រតិបត្តិតាម
# ព្រះពុទ្ធសាសនា


**និពន្ធដោយ**

**ព្រះតេជគុណ បណ្ឌិត ក. ស្រីធម្មានន្ទ**

**ប្រែ និងរៀបរៀងដោយ**

**ភិក្ខុ** មង្គលជោតោ **សឿង ឫទ្ធី**



**បោះពុម្ពលើកទី១**

ចំនួន ៥.000 ក្បាល

**ការផ្សាយរបស់**

**សមាគមសមណនិស្សិតខ្មែរ**

ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា

**ឧបត្ថម្ភបោះពុម្ពដោយ អង្គការព្រះធម៌ជំនួយអាស៊ី**

សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ

**ព.ស. ២៥៥៥**

ឈ្មោះសៀវភៅ : **ហេតុអ្វីយើងគប្បីប្រតិបត្តិតាមព្រះពុទ្ធសាសនា**

អ្នកបកប្រែ : **ភិក្ខុ** មង្គលជ្ជោតោ **សឿង វុទ្ធី**
Bhikkhu Soeurng Vutthy (Maṅgalajjoto)
E-mail: greatvutthy@gmail.com
Website: http://info-ksma.wikidot.com

បោះពុម្ពលើកទី១ : នៅថ្ងៃអាទិត្យ ១៥ កើត ខែ ស្រាពណ៍ ឆ្នាំ ថោះ ព.ស. ២៥៥៥ ត្រូវនឹង ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ចំនួនបោះពុម្ព : ៥.000 ក្បាល

តម្លៃ : ១.៤00 ដុល្លារ (១ ក្បាល = 0,២៨ ដុល្លារ)

អ្នកឧបត្ថម្ភ : **អង្គការព្រះធម៌ជំនួយអាស៊ី**

បោះពុម្ពដោយ : **រោងពុម្ព ម៉េង ហាវ**
ផ្ទះលេខ ៨១ ផ្លូវ ១៧២ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ
ក្រុងភ្នំពេញ, ទូរស័ព្ទ 0១២ ៨២៦ ៩២0

ផ្សាយចេញពី : **សមាគមសមណនិស្សិតខ្មែរ**
សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ, មីយ៉ាន់ម៉ា

អ្នកវាយអត្ថបទ : សាមណេរ **ហ៊ឹម សុខុម**

អ្នករចនាក្រប : **ភិក្ខុ** បញ្ញាវរោ **ស៊ុយ សុវណ្ណ**

# WHY WE SHOULD PRACTISE BUDDHISM

By
VENERABLE DR. K. SRI DHAMMANANDA

Translated and Prepared by
Bhikkhu Soeurng Vutthy (Maṅgalajjoto)

First Edition
5,000 copies

A Publication of
Cambodian Buddhist Student-Monks
Yangon, Myanmar

Sponsored by:
Dhamma Aid Asia
For Free Distribution Only

B. E. 2555 A. D. 2011

# មាតិកានុក្រម

ទំព័រ


- អារម្ភកថា ........ ក
- និវេទនកថា ........ គ
- ហេតុអ្វីយើងគប្បីប្រតិបត្តិតាមព្រះពុទ្ធសាសនា ........ ១
- សេចក្ដីទុក្ខ ........ ១១
- គំរូរបស់ព្រះសម្ពុទ្ធ ........ ១៣
- អភិនេស្រ្កមណ៍ ........ ១៤
- ពុទ្ធសាសនានៅប្រទេសចិន ........ ១៧
- ពុទ្ធសាសនានៅប្រទេសម៉ាឡេស៊ី ........ ២២
- ទស្សនាទានរបស់អ្នកប្រែរៀបរៀង ........ ២២
- សាសនាដែលពួកបញ្ញវន្តអាចឲ្យតម្លៃ ........ ២៦
- ឥរិយាបថរបស់សាសនាមួយចំនួន ........ ២៧
- របៀបរស់នៅតាមបែបសាសនាប្រកបដោយវិចារណញ្ញាណ ២៩
- ពុទ្ធសាសនា និងបច្ចេកវិទ្យាទំនើប ........ ៣៤
- មនុស្ស និងសាសនា ........ ៤២
- ចិត្តមនុស្សស្មានមិនត្រូវ ........ ៤៥

❁ សេរីភាពក្នុងការជ្រើសរើស ............................................ ៤៨
❁ សាសនា និងអ្នកគិតសេរី ................................................ ៥៣
❁ បុគ្គលដូចម្តេច ទើបឈ្មោះថាបាននៅជិតព្រះពុទ្ធ? .......... ៥៥
❁ ការប្រកាន់ភេទ និងការធ្វើទារុណកម្ម ............................... ៥៧
❁ ដាក់ទណ្ឌកម្មចិត្ត ........................................................... ៥៩
❁ សេចក្តីសន្និដ្ឋាន ........................................................... ៦១

# អារម្ភកថា

សៀវភៅដែលអស់លោកអ្នក និងប្អូនៗកំពុងកាន់អាននៅនឹងដៃនេះ ច្បាប់ដើមជាភាសាអង់គ្លេស។ តែដោយខ្ញុំបានអានហើយ ឃើញថាវាមានខ្លឹមសារល្អគួរយកជាគតិបាន ទើបខ្ញុំសម្រេចចិត្តបកប្រែជាភាសាខ្មែរ ដើម្បីបម្រើផលប្រយោជន៍អក្សរសាស្ត្រជាតិយើង។

ក្នុងការបកប្រែ និងសរសេរនេះពិតជាមានកំហុសឆ្គងខាងឃ្លាល្បះ អក្ខរាវិរុទ្ធ និងពាក្យបច្ចេកសព្ទមួយចំនួនមិនលែង។ ព្រោះខ្ញុំជាអ្នកបកប្រែមិនមែនជាអ្នកចេះដឹងជ្រៅជ្រះ មិនជាអ្នកវប្បធម៌អក្សរសាស្ត្រ ហើយក៏គ្មានសញ្ញាប័ត្រអ្វីធំដុំទេ។ ប៉ុន្តែគ្រាន់តែជាអ្នកមានឆន្ទៈ ក្នុងការធ្វើកិច្ចការនេះប៉ុណ្ណោះ។

ដូច្នេះសូមលោកអ្នក និងប្រិយមិត្តអ្នកអានមេត្តាជួយកែតម្រូវ នូវរាល់កំហុសឆ្គងដោយអចេតនានេះ ដើម្បីចូលរួមលើកតម្កើងតម្លៃភាសាជាតិយើងក្នុងគោលបំណង បម្រើផលប្រយោជន៍រួមរបស់សង្គម ។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះ ពិតជាជំនួយយ៉ាងសំខាន់សំរាប់សិក្ខាកាម កុលបុត្រក្នុងសកលកម្ពុជារដ្ឋ និងជាពិសេសសិស្សានុសិស្សវិទ្យាល័យនានា។ ព្រោះនៅក្នុងប្រធានបទ

នីមួយៗ សុទ្ធតែផ្ទុកទៅដោយគំនិតសំខាន់ ដែលអាចទុកដូចជាពុទ្ធិខាងវប្បធម៌ទូទៅមួយផ្នែកដែរ ។

ភិក្ខុ សឿង ទុន្ធី

## និវេទនកថា

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក **យូ ធាន** និងសប្បុរសជនជើងវត្តមហាវិហារទាំងអស់ នៅប្រទេសម៉ាឡេស៊ី ដែលបានខ្នះខ្នែងរកថវិកាជួយបោះពុម្ពសៀវភៅនេះ ឲ្យចេញជារូបរាងឡើង ដើម្បីចែកជូនជាធម្មទាន ដល់សាធារណជនទូទៅ។

សូមអរគុណឧបាសិកា **គិម ស៊ីមឿន** សីលវន្ត សីលវតី នៅពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែយកចិត្តទុកដាក់ ក្នុងការឧបត្ថម្ភបច្ច័យបួន និងគ្រឿងឧបភោគ បរិភោគផ្សេងៗ ដល់សមណនិស្សិត និងនិស្សិតខ្មែរ ដែលបាននិងកំពុងសិក្សារៀនសូត្រ ក្នុងផ្លូវពុទ្ធសាសនា នៅសហភាពមីយ៉ាន់ម៉ា។

សូមអរគុណចំពោះឧបាសក **ម៉ៅ វ៉ាន** និងឧបាសិកា **ធន់ សំបូរ** អតីតទីប្រឹក្សា ឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា និងមហាឧបាសិកា **ភាំង ឃ្លិចណៃ** ព្រមទាំងក្រុមគ្រួសារទាំងអស់ និងសូមអរគុណចំពោះបងស្រី **តី សុភា** និងស្វាមី ព្រមទាំងបុត្រ ដែលជួយឧបត្ថម្ភដល់សមណនិស្សិត និងនិស្សិតខ្មែរយើង នៅសហភាពមីយ៉ាន់ម៉ារឿយៗ។ បើគ្មានអ្នក

ឧបត្ថម្ភទំនុកបម្រុងដូច្នេះទេ ធនធានមនុស្ស និងពុទ្ធសាសនា យើងពុំអាចរីកចម្រើនបានដូច្នេះឡើយ។

សូមថ្លែងអំណរគុណផងដែរចំពោះលោក **សេក សឿន** និងភរិយា **សម សាមន** នៅសហរដ្ឋអាមេរិក, បណ្ឌិត **ថៃល ថោង** និងភរិយា, លោក **គឹម សាន** ព្រមទាំងគ្រួសារ នៅប្រទេសអូស្រ្តាលី ដែលឧបត្ថម្ភខ្ញុំនូវបច្ច័យបួនមួយចំនួន ក្នុងពេលកំពុងបំពេញការសិក្សា។

លើសពីនេះទៀត ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរគុណសមណនិស្សិត និងនិស្សិត ជាសហការីទាំងអស់ដែលបានជួយក្នុងកិច្ចការជាកុសលនេះ ឲ្យបានសម្រេចជាស្ថាពរ។ នាមសមណនិស្សិត និងនិស្សិត ជាអ្នកជំនួយការក្នុងការរៀបចំសៀវភៅនេះ មានដូចជា៖

- ភិក្ខុ **ស៊ិន គង់** សមណនិស្សិតអនុបណ្ឌិត
- ភិក្ខុ **ស៊ុយ សុវណ្ណ** សមណនិស្សិតអនុបណ្ឌិតឆ្នាំទីមួយ
- លោក **ព្រំ ស៊ីណា** និស្សិតថ្នាក់បរិញ្ញាបត្រ

ដោយអំណាចនៃវិរិយភាព និងសទ្ធាជ្រះថ្លា ក្នុងការជួយធ្វើសៀវភៅនេះឲ្យបានសម្រេច និងការជួយរកថវិការបោះពុម្ពសៀវភៅនេះ ជាដើម សូមឲ្យព្រះអង្គ និងលោកអ្នកមានគុណ

បំណាច់ទាំងអស់ បានជួបប្រទះនូវសេរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ។ ទីបំផុត សូមឲ្យបានសម្រេចមគ្គផល និងព្រះនិព្វាន រួចចាកទុក្ខក្នុងសំសារៈ ឬបើប្រាថ្នាយ៉ាងណាៗ សូមឲ្យបានសម្រេចដូចសេចក្តីប្រាថ្នានោះចុះ។

សូមអរព្រះគុណ និងអរគុណ!

# ហេតុអ្វីយើងគប្បីប្រតិបត្តិតាមព្រះពុទ្ធសាសនា

មុនយើងចាប់ផ្ដើមជជែកថាតើហេតុអ្វី យើងគប្បីប្រតិបត្តិតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធនោះ យើងគប្បីយល់ថា ហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្រេចព្រះទ័យបង្រៀននូវមាគ៌ាជីវិតថ្មីមួយ តាមបែបសាសនា ដើម្បីបានសម្រេចសេចក្ដីសុខ ថ្នាក់ទីបំផុតជាលើកដំបូង ។

លោកអ្នកប្រហែលចាំបានថា ដំបូងព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះទ័យរួញរា ដើម្បីប្រកាសនូវឱវាទនេះ ព្រះអង្គទ្រង់ឈ្វេងយល់ឃើញពីមនុស្ស ដែលមានការភ័ន្តច្រឡំដោយពិតអំពីជីវិតរបស់ពួកគេ លក្ខណៈរបស់គេ និងរបៀបខុសគ្នាទាំងស្រុង នៃវិធីសាស្ត្ររបស់ព្រះអង្គដែលស្ដែងចេញពីអ្វី ដែលពួកគេធ្លាប់បានពើបប្រទះពីមុនមក ។

ព្រោះហេតុដូច្នេះ នៅពេលដែលព្រះអង្គទ្រង់ប្រមើលឃើញថាមាន “សត្វពួកខ្លះៗដែលមានធូលីក្នុងភ្នែកតិច” ព្រះអង្គក៏បានសម្រេចចិត្តផ្សព្វផ្សាយ នូវសច្ចធម៌នេះទៅដល់ពពួកជនទាំងឡាយ។

ព្រះអង្គចែកចាយធម្មៈនេះ ចេញពីព្រះទ័យមេត្តាដ៏បរិសុទ្ធ

ដើម្បីរំដោះទុក្ខរបស់សត្វលោក ។

មាគ៌ាត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងជាតិចុងក្រោយរបស់ព្រះអង្គ បានចាប់ផ្តើមនៅពេលដែលព្រះអង្គទ្រង់បានទតឃើញនូវទេវទូតទាំងបួនគឺ៖ មនុស្សចាស់ជរា១ មនុស្សឈឺ១ សាកសព១ និងភេទអ្នកបួស១ ដែលធ្វើឲ្យព្រះអង្គជ្រាបបានយ៉ាងច្បាស់ដោយបញ្ញាញាណថា សេចក្តីទុក្ខគឺបណ្តាលមកពីសេចក្តីតូចចិត្ត សេចក្តីមិនពេញចិត្ត និងសេចក្តីបង្អៀតចង្អល់ចិត្ត ។

ក្សណៈនោះ ព្រះអង្គបានអធិដ្ឋានចិត្តយ៉ាងមាំ ហើយក៏បានបន្សាត់ខ្លួន ចេញចាកផ្លូវលោក និងចាប់ផ្តើមស្វែងរកនូវមាគ៌ារំលត់ទុក្ខគ្រប់យ៉ាង តាមអង្គអរិយមគ្គ ។

ព្រះអង្គទ្រង់កត់សំគាល់ឃើញថា សេចក្តីទុក្ខលំបាកនេះជាហេតុបង្កើត ឲ្យមានអំពើអាក្រក់ផ្សេងៗនៅក្នុងសង្គម រួមមានទាំងការរើសអើងជាតិសាសន៍ និងការយល់ឃើញខុសជាដើម ។

ព្រះអង្គក៏បានឃើញបុគ្គល ដែលកំពុងព្យាយាមរំខ្លួនចេញពីសេចក្តីទុក្ខ បានក្លាយខ្លួនទៅជាទាសករចំពោះការប្រតិបត្តិសាសនាដូចជា ការបង្អត់អាហារ និងការប្រព្រឹត្តអត្តកិលមថា-

នុយោគ ស្ថិតនៅក្រោមអំណាចរបស់មិច្ឆាទិដ្ឋិ ដោយយល់ឃើញថា ការធ្វើខ្លួនឲ្យលំបាកដូច្នេះអាចធ្វើឲ្យពួកគេ លះបង់នូវអ្វីដែលគេហៅថាអាត្មន័ ។

ព្រះអង្គទ្រង់បានមើលឃើញ នូវសេចក្ដីទុក្ខមានកម្រិតដ៏ធំក្រៃលែង ដែលកើតឡើងដោយការបែងចែកវណ្ណៈមនុស្សជាបួនថែមទៀត ។

ឯស្ត្រីទាំងឡាយក៏ទទួលរង នូវការប្រកាន់គេទយ៉ាងគួរឲ្យខ្លាចផងដែរ។ ហើយចំនួនប្រាក់កាសដ៏ច្រើនសន្ធឹកសន្ធាប់ ត្រូវបានចំណាយទៅលើកិច្ចការដែលគ្មានខ្លឹមសារ ដែលបណ្ដាលឲ្យស្លាប់បាត់បង់ជីវិត របស់សត្វទាំងឡាយដោយគ្មានពំនឹង ។ ព្រះពុទ្ធទ្រង់ឈ្វេងយល់ឃើញថា បញ្ហាទាំងអស់នេះគឺគ្មានអ្វីក្រៅពីការពាក់ព័ន្ធ ដោយការយល់ដឹងផ្នែកសតិបញ្ញាពីស្ថាន-ភាពមិនសមស្របរបស់មនុស្សជាតិ ហើយព្រះអង្គទ្រង់មានបំណងចង់បង្ហាញនូវផ្លូវត្រូវ សម្រាប់សង្គ្រោះដល់ជនទាំងនោះ ។

ព្រះអង្គប្រាថ្នាចង់ណែនាំ នូវមាគ៌ាជីវិតដ៏ប្រសើរ ដល់មនុស្សលោក នូវកិច្ចប្រតិបត្តិដើម្បីស្ដារឡើងវិញ នូវសេចក្ដីថ្លៃថ្នូរតាមបែបបវេណីរបស់ខ្លួន ។ ព្រះអង្គទ្រង់បានប្រកាសថា

សង្គហកិច្ចពិតជាត្រូវទទួលបាន តាមរយៈការដុសខាត់ជម្រះចិត្ត និងទទួលបាននូវបញ្ញា នេះមិនមែនសម្រេចបានដោយបណ្ដុះគំនិត បណ្ដុះនិស្ស័យ ក្នុងជំនឿទាំងងងឹតងងល់ ឬក៏សេចក្ដីភ័យខ្លាចចំពោះអាទិទេព និងបញ្ហារបស់អាទិទេពនោះទេ ។

នៅត្រង់ចំនុចនេះ ចាំបាច់ត្រូវដឹងពីលក្ខណៈប្លែកគ្នារវាងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលយើងហៅថាធម៌ និងសាសនា ជាពុទ្ធសាសនាដែលមានសកម្មភាពជាប់ទាក់ទងនឹងបញ្ហារបស់សង្គម ដែលត្រូវបានបង្កើតឡើងដោយសាវ័ករបស់ព្រះអង្គ ដោយអនុលោមទៅតាមប្រពៃណីទំនៀមទម្លាប់ និងមាគ៌ាជីវិតរបស់ពួកគេ។ ព្រះពុទ្ធមិនមានបំណងបង្កើតសាសនាដើម្បីឲ្យជនទាំងឡាយជឿតាមនោះទេ ។

ក្នុងឱកាសជាច្រើន ព្រះអង្គទ្រង់បានប្រកាសថា ព្រះអង្គមិនបានចាប់អារម្មណ៍ថា ជនណាមួយបានផ្ដល់នូវកិត្តិយសដល់ព្រះអង្គ ឬក៏អត់នោះទេ ។

ផ្ទុយទៅវិញ ព្រះអង្គបានលើកទឹកចិត្ត ដល់សាវ័កទាំងឡាយ ឲ្យចេះពិចារណាបានស៊ីជម្រៅនូវឱវាទទាំងឡាយ ដើម្បីសម្រេចចិត្តថា តើឱវាទនោះមានសុពលភាពដែរ ឬមិនមាន ។

ព្រះអង្គទ្រង់មិនបានដាក់ទោស ទៅលើជនណាដែលមិនបានធ្វើតាមបញ្ញារបស់ព្រះអង្គឡើយ ព្រះធម៌ដែលព្រះសម្មា-សម្ពុទ្ធទ្រង់បានត្រាស់ដឹង និងទ្រង់បានបង្រៀននោះ ត្រូវបានស្រាយបំភ្លឺថា ជាអរិយសច្ចៈ។ ព្រោះធម៌នេះ បានបង្ហាញឲ្យយើងឃើញពីភាពពិតនៃជីវិតរបស់យើង និងជួយដឹកនាំខ្សែជីវិតបានត្រឹមត្រូវប្រាសចាកទោស និងស្វែងរកបាននូវសិទ្ធិសេរីភាព ។

ពាក្យថាធម្មៈ កើតមកពីពាក្យឫសថា "ធរ" មានន័យថា "ឧបត្ថម្ភ" ឬ "ទ្រទ្រង់"។ ដូចនេះហើយទើបធម៌នេះមានឈ្មោះថា បរមត្ថសច្ចៈ ក្រៅពីនោះគឺជាអំពើ ឬជាច្បាប់សកល។ ការដឹងដល់ថ្នាក់សច្ចៈដូចនេះ អាចកម្ចាត់បង់នូវអវិជ្ជា និងជួយឲ្យយើងបានរួចរំដោះ ចាកផុតសេចក្ដីភ័យខ្លាច និងជំនឿច្រើន ។

ធម៌នោះអាចជួយយើង ឲ្យសម្រេចបាននូវការសង្គ្រោះរបស់យើងដោយខ្លួនឯង ។ ព្រះធម៌រមែងគាំពារយើងមិនឲ្យធ្លាក់ទៅក្នុងកំណើតអបាយភូមិ ទាំងក្នុងលោកនេះ និងលោកខាងមុខដែលអាចកើតជាសត្វតិរច្ឆាន អសុរកាយ និងប្រេតជាដើម ។

ប៉ុន្តែសូមកុំភ្លេចថាៈ យើងមិនត្រូវរង់ចាំដល់ស្លាប់ ទើបបានដឹងនូវសភាវៈទាំងនេះទេ សូម្បីតែយើងកំពុងមានជីវិតរស់នៅ

ជាមនុស្ស ក៏យើងបញ្ចេញនូវសេចក្តីក្រោធ ទោសៈ លោភៈ ឥស្សា ហើយក៏ធ្លាក់ខ្លួនទៅជាសត្វទាំងនេះបានដែរ ។

នៅពេលយើងបង្កើននូវសន្តានចិត្ត ប្រកបដោយកិលេសទាំងនេះ ជាឫសគល់របស់វា ដូចនេះយើងច្បាស់ជាបានឃើញនូវកំណើតជាឧបបាតិកៈនោះ ក្នុងពេលចុតិ និងបដិសន្ធិក្នុងស្ថានថោកទាបនេះជាមិនខាន ។

ការដឹងនូវដំណើរទាំងនេះឲ្យឈ្មោះថា ធម្មៈ ឬ ធម៌ដែលជាសភាវៈទ្រទ្រង់យើងមិនឲ្យធ្លាក់ទៅក្នុងសេចក្តីទុក្ខ ក្នុងស្ថានអបាយ និងវដ្តសង្សារ ។

ដូចនេះយើងបានដឹងថា ពាក្យ "ធម៌" មានការបកស្រាយស្រដៀងគ្នា នឹងពាក្យ "សាសនា" ដែលជាប្រព័ន្ធជំនឿជាទំនៀម និងជាព្រហ្មចរិយៈ. . .។

ដូចនេះហើយ ទើបព្រហ្មចរិយធម៌នេះជាមាគ៌ាដើម្បីហ្វឹកហាត់ និងដុសខាត់ជម្រះចិត្តដោយពិត។ ធម្មជាតិពិតរបស់ចិត្តមនុស្សមិនត្រូវបានពន្យល់ឲ្យបានច្បាស់លាស់ នៅក្នុងសាសនាដទៃទេ ការបកស្រាយពិតខាងសកម្មភាពផ្លូវចិត្ត អាចត្រូវបានគេរកឃើញនៅក្នុងគម្ពីរអភិធម្ម គម្ពីរមានអត្ថជ្រាលជ្រៅ ក្នុងពុទ្ធសាសនា ។ អ្នកចិត្តវិទ្យាសម័យទំនើប គឺស្ថិតនៅក្នុងភាព

អាចរិកំបាំងនៅឡើយ អំពីវិស័យនៃចិត្តមនុស្សខ្លះ ។ ប៉ុន្តែពួកអ្នកចិត្តវិទ្យាទាំងនោះ បានទទួលស្គាល់ថា ពេលយើងប្រៀបធៀបចិត្តវិទ្យាសម័យថ្មី ជាមួយនឹងចិត្តវិទ្យាដែលគង់នៅជាង ២៥០០ ឆ្នាំ ក្នុងប្រទេសឥណ្ឌា ចិត្តវិទ្យាសម័យថ្មីកំពុងស្ថិតនៅក្នុងជំហាននៃការចាប់ផ្តើមនៅឡើយ ។

ព្រះពុទ្ធបានពន្យល់យ៉ាងច្បាស់នូវរឿងរ៉ាវទាំងឡាយ ដែលមនុស្សមិនអាចយល់ឃើញជាមុន ។ ពិតមែនហើយ នៅពេលយើងឃើញនូវធម្មជាតិពិតនៃចិត្តរបស់មនុស្ស យើងគង់អាចយល់បានថា ហេតុអ្វីខ្លួនយើងត្រូវបាន គេហៅថា "មនុស្ស" ។ "មន" មានន័យថាចិត្ត បន្ថែមពាក្យ "ឧស្ស" បានជា "មនុស្ស" មានន័យថា អ្នកដែលអាចធ្វើឲ្យចម្រើន បណ្តុះចិត្តរបស់ខ្លួនឲ្យឈានដល់ថ្នាក់ខ្ពស់បំផុត (ឬអ្នកដែលដឹងនូវហេតុដែលមានប្រយោជន៍ និងមិនមានប្រយោជន៍) ។

ក្នុងរបៀបដូចគ្នានេះ ទស្សនវិជ្ជាចិនប្រើពាក្យ "**Humane**" "**Ren**" ដើម្បីពណ៌នាចំពោះជនណាដែលមានមេត្តា ករុណា មុទិតា និងសេចក្តីទៀងត្រង់ ។ ប្រសិនបើគុណធម៌ទាំងនេះមិនមាននៅក្នុងខ្លួនមនុស្សទេនោះ យើងមិនអាចចាត់ទុកអ្នកនោះជាមនុស្សពិតបានទេ ។

ឯទស្សនវិជ្ជាលោកខាងលិចវិញ កំណត់ពាក្យនេះ ដោយសំដៅដល់ជនទាំងឡាយណាដែលមានវិចារណញ្ញាណ ប្រកបដោយហេតុផល។ តាមពិតទៅ ពាក្យ “**Homo Sapien**” មានន័យចំថា អ្នកមានប្រាជ្ញា ឬអ្នករិះគិត ។ មនុស្សទាំងអស់សុទ្ធតែមានចិត្តដូចគ្នា ប៉ុន្តែចិត្តមនុស្សខ្លះនៅមានកម្រិត គ្រាន់តែដើម្បីធ្វើឲ្យជាក់ច្បាស់ដល់ជីវិតរបស់ពួកគេ ដែលកំពុងរស់នៅដើម្បីជួយពួកគេស្វែងរកអាហារ លំនៅដ្ឋាន ដើម្បីប្រពន្ធកូន និងសេចក្តីសប្បាយបន្តិចបន្តួចប៉ុណ្ណោះ ។ តែគេមិនអាចពង្រីកចិត្តរបស់គេឲ្យបានវែងឆ្ងាយជាងនេះទៀតទេ ។

សូម្បីតែទេវតា ព្រះព្រហ្មដែលតាំងខ្លួនឯងជាអាទិទេព ឬអច្ឆរិយបុគ្គលនោះ ក៏គ្មានបញ្ញាដូចមនុស្សយើងដែរ ។ ពួកទេវតា និងព្រហ្មទាំងនោះ ក៏មិនដឹងនូវអ្វីដែលនឹងកើតឡើងចំពោះពួកគេបន្ទាប់ពី ចុតិ (ការស្លាប់) ឡើយ ។ គឺពួកទេវតា ឬព្រហ្មទាំងនោះ មិនដឹងពីរបៀបរៀបចំដំណើរ សម្រាប់ជីវិតបរលោកនាយរបស់ខ្លួន ហើយក៏គ្មានគំនិតរបៀបនេះដែរ ។

ជំនឿថា ការកើតជាទេវៈ ឬព្រហ្មគួរជាទិសដៅចុងក្រោយនៃជីវិតរបស់យើងនោះ ត្រូវបានព្រះសម្មាសម្ពុទ្ធបដិសេធទៅវិញ។ ដរាបណាចំណង់ ក្នុងភពនៅមានក្នុងសត្វណា សត្វនោះ

ឯងវមែងនៅកើតទៀត ។ យើងហៅ ចំណង់តណ្ហាដ៏ធំនោះថា ភវតណ្ហា (សេចក្ដីប្រាថ្នាក្នុងភព) ។ ម្យ៉ាងហើយ ពួកទេវតា និងព្រហ្មដែលមានចំណង់តណ្ហាមាំ ក៏មិនអាចជៀសផុត ពីបដិ-សន្ធិ ប៉ុន្តែទេវតា និងព្រហ្មទាំងនោះមិនអាចដឹងដូច្នេះទេ ។ ឯមនុស្សអាចដឹងថា ការស្លាប់មិនមែនជាចុងបញ្ចប់នៃជីវិតទេ គឺជីវិតនោះអាចប្រព្រឹត្តទៅជាបន្តទៀត ។

ហេតុនេះហើយ សត្វទាំងឡាយដែលមានបញ្ញា នៅក្នុងស្ថាន ដែលដឹងដូច្នេះ គប្បីរៀបចំសម្រាប់ដំណើរជីវិតភពខាងនាយនោះចុះ និងគប្បីជ្រាបច្បាស់ថា ស្ថាននោះមិនមែនជាស្ថានទុគ្គតិឡើយ។ នេះហើយដែលថា សាសនាក្លាយជាជំនួយ (ដល់សង្គម) ដ៏មានសារៈសំខាន់នោះ ។

មនុស្សទាំងឡាយគឺជាសត្វតែមួយគត់ ដែលអាចដឹងថា យើងមានអានុភាព ដើម្បីគ្រប់គ្រងជោគវាសនារបស់ខ្លួនយើងផ្ទាល់ ។

គ្មានបុគ្គលដទៃណាអាចបង្កើតសាសនាបានទេ ។ មានតែមនុស្សទេ ទើបអាចបង្កើត និងរៀបចំសាសនាបាន ដោយសារបញ្ញាញាណរបស់ខ្លួនឯង ។

ជំនឿសាមញ្ញជឿថា សាសនាទាំងឡាយមានភពកំណើត

នៅឋានសួគ៌ ហើយបានត្រូវនាំយកមកកាន់លោកនេះ ដោយការផ្សព្វផ្សាយឲ្យដឹង ។ ប៉ុន្តែពុទ្ធសាសនាមានដើមកំណើតនៅលើកពផែនដីនេះ តាំងនៅក្នុងចិត្ត មនុស្សទាំងឡាយរួចក្រោយមក ទើបបានឈានទៅដល់ស្ថានសួគ៌ ។

សាសនាមិនមែនមកពីលើស្ថានសួគ៌ទេ ។

តាមពិតទៅ ស្ថានទេវតា (ឋានសួគ៌) ទាំងឡាយនោះមិនដែលនាំឲ្យមាននូវសេចក្តីចម្រើនល្អតលាស់ ខាងប្រាជ្ញាស្មារតីទេ ព្រោះស្ថានទាំងនោះ ខ្វល់ខ្វាយតែជាមួយនឹងសេចក្តីសុខតែម្យ៉ាង ។ ហើយទេវតាទាំងឡាយមិនបាននឹកគិតដល់សភាពពិតនៃការមិនទៀង និងសេចក្តីទុក្ខឡើយ។

តទៅនេះ ជាការពន្យល់ឲ្យដឹងថាហេតុអ្វីបានជាព្រះសម្មា-សម្ពុទ្ធ បានត្រូវច្យុតចាកពីឋានតុសិតមកកាន់លោកនេះ ដែលជាព្រះអង្គបានកំពុង គង់នៅដូចជាទេវៈមួយអង្គ ដើម្បីសម្រេចបាននូវការត្រាស់ដឹង ។ តាមពិត អាទិទេព ឬទេវៈ និងព្រះព្រហ្មមិនអាចក្លាយជាព្រះពុទ្ធបានទេ មានតែមនុស្សប៉ុណ្ណោះទើបអាចអប់រំចិត្តរបស់ខ្លួន ឲ្យឈានទៅដល់ការបំពេញដល់កម្រិតនោះបាន ព្រោះពួកគេកំពុងស្ថិតនៅក្នុងឋានៈមួយ ដើម្បីពិនិត្យពិច័យនូវធម្មជាតិ នៃសេចក្តីទុក្ខទាំងឡាយ ។

ឥឡូវនេះយើងអាចយល់បានថា ខ្លួនយើងជាមនុស្សពិតៗ មានសក្តានុពលដើម្បីអាចបណ្តុះចិត្តរបស់យើង រហូតឈាន ដល់ព្រះនិព្វាន ជាការឃើញនូវទីបំផុតនៃសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្តទាំងឡាយទាំងពួង ឬសេចក្តីតូចចិត្តនោះ ។ ដោយខ្វះ បញ្ញាយល់ដឹងពីសច្ចធម៌នេះ ទើបមានមនុស្សពួកខ្លះព្យាយាម ចំអកព្រះពុទ្ធ ដោយការនិយាយថា ព្រះពុទ្ធមិនមែនជាតួអង្គ អាទិទេពទេ ។ ហើយក៏តាំងសំនួរឡើងថា "ហេតុអ្វីបានជាអ្នក ធ្វើសក្ការបូជាដល់ព្រះអង្គ?" "តើអ្នកទទួលបានអ្វីពី ព្រះអង្គ ទៅ?" ប្រសិនបើយើងឲ្យតម្លៃថា ព្រះសម្មាសម្ពុទ្ធជាអាទិទេព មួយអង្គមែននោះ យើងបន្ទាបបន្ថោកនូវពោធិញ្ញាណ របស់ ព្រះអង្គហើយ ។

# សេចក្តីទុក្ខ

យើងទាំងអស់គ្នា សុទ្ធតែទទួលសោយនូវអារម្មណ៍ជាទុក្ខ នេះ ។

តើយើងទទួលនូវអារម្មណ៍ជាទុក្ខបែបនេះ ប៉ុន្មានដងក្នុង មួយថ្ងៃ?

ត្រង់ហ្នឹងហើយដែលព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិថាជា "ទុក្ខ"

មិនមែនចាំបាច់សំដៅដល់ការឈឺចាប់ ឬសេចក្ដីសោកសៅនោះទេ នេះជារបៀបកំណត់ដឹងធម្មតានៃពាក្យនេះ ។

យើងរមែងទទួលនូវអារម្មណ៍ជាទុក្ខទោមនស្សនេះ ។ យើងមិនដែលពេញចិត្តទៅនឹងអ្វី ដែលយើងបាននោះទេ យើងរឹតតែចង់បានរបស់នោះហើយ ចង់បានទៀត ។

យើងចង់បោះបង់របស់នោះចោល នៅពេលដែលយើងបានវាហើយ ព្រោះរបស់នោះបាត់បង់នូវភាពទាក់ទាញរបស់វា ។

យើងហៅការបាត់បង់នេះថា ភាពមិនទៀង ។ ដូច្នេះមួយជីវិតរបស់យើងៗ ព្យាយាមប្រកាន់ខ្ជាប់ទៅនឹងរបស់ទាំងនោះ។ ហើយយើងតែងតែទទួលនូវអារម្មណ៍ជាទុក្ខជានិច្ច ព្រោះខ្លួនយើងផ្ទាល់ និងវត្ថុទាំងឡាយដែលយើងប្រកាន់មាំនោះតែងតែមានការប្រែប្រួលជាដរាប ។

ភាពសប្បាយរីករាយពិតប្រាកដនោះ គឺនៅត្រង់យើងត្រូវចេះជំនះលើចំណុចខ្សោយ របស់យើងហ្នឹងឯង ។ ហើយព្យាយាមដើម្បីដឹងថា ហេតុអ្វីបានជាយើងមិនសប្បាយចិត្ត ។ នេះទើបជាគោលបំណងក្នុងជីវិតពិតរបស់យើង ។

# គំរូរបស់ព្រះសម្ពុទ្ធ

គំរូរបស់អង្គព្រះសម្មាសម្ពុទ្ធផ្ទាល់ សមល្មមគ្រប់គ្រាន់ ដើម្បីពន្យល់ពី វិធីដែលយើងអាចធ្វើដំណើរតាមផ្លូវ ឆ្ពោះទៅរកភាពបរិសុទ្ធបាន ។ ការហ្វឹកហាត់ដំណើររបស់ព្រះពោធិសត្វ មុនពេលដែលព្រះអង្គបានក្លាយជាព្រះពុទ្ធមួយអង្គ គឺជាដំណើរមួយដ៏វែងឆ្ងាយ និងលំបាកលំបិន ។

រឿងរ៉ាវទាំងឡាយ ក្នុងគម្ពីរជាតកបានដំណាលពីជាតិរបស់ព្រះសម្ពុទ្ធច្រើនរាប់មិនអស់ ដែលព្រះអង្គទ្រង់បានឆ្លងកាត់នូវការសាកល្បងជាច្រើន ដើម្បីជម្រះចិត្តឲ្យបរិសុទ្ធ ។ សូម្បីក្នុងកំណើតចុងក្រោយរបស់ព្រះអង្គ កាលនៅជាព្រះសិទ្ធត្ថ ព្រះអង្គធ្លាប់បានទទួលការសាកល្បងវិនិច្ឆ័យជាច្រើនដង មុនការត្រាស់ដឹង ។ សូម្បីកាលនៅជាកុមារ ថ្ងៃមួយនោះព្រះអង្គបានទតឃើញសត្វបង្កួយកំពុងស៊ីស្រមោច សត្វពស់ក៏បានលេបសត្វបង្កួយនោះ រួចហើយសត្វពស់នោះក៏ត្រូវសត្វស្ទាំងចឹកស៊ីទៀត ។ ព្រឹត្តិការណ៍ជាប់តៗគ្នាទាំងនេះ បានធ្វើឲ្យព្រះអង្គនឹកឃើញដល់ធម្មជាតិនៃសេចក្តីទុក្ខ ដែលសត្វទាំងឡាយបៀតបៀនលើគ្នា និងគ្នាចំពោះជីវិតរស់នៅរបស់ពួកគេ ។

ថ្ងៃមួយជាខាងក្រោយមក ទេវទត្តត្រូវជាបងប្អូនជីដូនមួយ

របស់ព្រះអង្គ បានបាញ់សត្វហង្សមួយ ធ្វើឲ្យរបួស ហើយព្រះអង្គក៏នាំយកមកព្យាបាល និងពន្យល់បញ្ចុះបញ្ចូលទេវទត្តថា មេត្តាគឺជាថ្នាំបន្សាបចំពោះអំពើឃោរឃៅ ដែលសត្វលោករមែងបៀតបៀនគ្នា។

អ៊ីចឹងហើយ បានជាពេលដែលព្រះអង្គបានឃើញនូវនិមិត្តទេវទូតទាំងបួន រួមមានមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងភេទអ្នកបួសនោះ ក៏បានធ្វើឲ្យព្រះអង្គនឹកឃើញដល់សេចក្តីពិតដ៏ក្រៃលែង ពីការមិនទៀងថាជាទុក្ខសច្ចៈ (ការពិតអំពីហេតុដែលនាំឲ្យកើតទុក្ខ) ។

ការដឹងនេះ បានធ្វើឲ្យឈានទៅដល់ការសម្រេចចិត្តរបស់ព្រះអង្គ ដើម្បីបកថយក្រោយ ចេញពីផ្លូវលោកដែលប្រកបទៅដោយផាសុកភាព ខាងផ្នែកសម្ភារៈ ដើម្បីចេញសាងមហាអភិនេស្ក្រមណ៍ (ការលះបង់ទ្រព្យសម្បត្តិ ប្រពន្ធកូន ដើម្បីចេញសាងផ្នួសប្រព្រឹត្តព្រហ្មចរិយធម៌) ។

## អភិនេស្ក្រមណ៍

សព្វថ្ងៃនេះ មានជនជាច្រើនយល់ថា វាជារឿងមួយលំបាកដើម្បីទទួលយកនូវសេចក្តីសម្រេចចិត្តតាមព្រះសិទ្ធត្ថ ដើម្បី

លះបង់ភរិយា និងបុត្រ ហើយចេញបព្វជ្ជានោះ ។ នេះមិនមែនជាការសម្រេចចិត្តដ៏សាមញ្ញមួយទេ នៅក្នុងវប្បធម៌របស់ប្រទេសឥណ្ឌា ដែលជាប្រទេសតែងតែបានប្រារព្ធធ្វើអរិយមគ្គដែលបុគ្គលអាចធ្វើបាន គឺការចេញសាងអភិនេស្រ្កមណ៍នេះឯង ។

ដើម្បីបង្អន់នូវការសប្បាយផ្លូវកាយ ហើយស្វែងរកការបំពេញសេចក្តីព្យាយាមខាងប្រាជ្ញាស្មារតី ។ នេះទើបបានឈ្មោះថាការសម្រេចចិត្តមួយ ដែលនាំមកនូវកិត្តិយសដល់គ្រួសារ ។ ទោះជានៅពេលយប់នោះ មុនពេលដែលព្រះសិទ្ធត្ថយាងចេញសាងផ្នួស ព្រះអង្គមិនបានជាស់ភរិយា និងបុត្រក៏ដោយ ក៏យើងដឹងដែរថា ព្រះអង្គបានពិគ្រោះពីបញ្ហានេះជា-មួយភរិយាជាច្រើនលើកច្រើនគ្រាដែរ ។ យើងដឹងទៀតថា ព្រះនាង**យសោធរាពិម្ពា** ក៏បានយល់ និងគាំទ្រនូវសេចក្តីសម្រេចចិត្តនោះ ដោយអះអាងថាព្រះនាង ក៏បានជ្រាបពីបំណងវាសនារបស់ព្រះអង្គដែរហើយ ។

នេះក៏ជាការរក្សាបវេណី របស់ឥណ្ឌាដូចដែលយើងបានឃើញ បានដឹង នៅក្នុងរឿងរាមាយណៈ (រឿងរាមកេរ្តិ៍) ស្រាប់ៗដែលនៅក្នុងនោះ នាង**សិតា** បានគាំទ្រយ៉ាងស្មុគ្រស្មោះនូវការ

សម្រេចចិត្តរបស់ព្រះរាម ហើយបានយល់ព្រម ឲ្យព្រះរាម ចេញទៅបួសជាតាបស រយៈពេល ១៤ ឆ្នាំ នៅក្នុងព្រៃ ។ នាងពិម្ពា ភរិយារបស់ព្រះសិទ្ធត្ថបានយល់ពីឱកាសដ៏ប្រសើរ ក្រៃលែងរបស់ព្រះអង្គ ដើម្បីជួយស្រោចស្រង់នូវសព្វសត្វ ទាំងអស់ នាងឥតមានចំណែកចិត្តអត្តទត្តភាព ដើម្បីហាមឃាត់ នូវដំណើររបស់ព្រះអង្គ ឲ្យខុសពីព្រះរាជបំណងឡើយ ។

បន្ទាប់ពីបានសាងផ្នួសមក ព្រះអង្គបានចាប់ផ្ដើមប្រតិបត្តិ នូវវិធីតបកម្មយ៉ាងតឹងតែង ដែលក្រោយមកព្រះអង្គបានយល់ ឃើញថា គ្មានប្រយោជន៍ និងមិនអាចនាំទៅរកសេចក្ដីស្ងប់ ចិត្ត ។

ព្រះអង្គទ្រង់ឈ្វេងយល់ឃើញថា នៅពេលរាងកាយត្រូវ បានធ្វើទារុណកម្មដោយការបង្អត់អាហារ និងបាត់បង់សេរីភាព ដូច្នេះ ចិត្តនោះមិនអាចស្ងប់ដើម្បីពិចារណាដោយសុវត្ថិភាព ទៅលើវត្ថុទាំងឡាយ តាមសភាវៈពិតបានទេ ។

ព្រះអង្គបានជ្រាបទៀតថា កាលនៅជាស្ដេចចក្រ ជីវិតរបស់ព្រះអង្គ ប្រកបទៅដោយវត្ថុប្រណីតហួសប្រមាណ មិនត្រឹមតែគ្មានប្រយោជន៍ទេ តែថែមទាំងធ្វើឲ្យអាប់អោន និង គួរឲ្យខ្មាសអៀនទៀតផង ។

ម្ល៉ោះហើយព្រះអង្គក៏ចាប់អនុវត្តតាមមជ្ឈិមបដិបទា វៀង វត្តប្រណីត និងតបកម្ម ហើយក៏បានរកឃើញនូវរូបមន្តត្រឹមត្រូវ សម្រាប់អប់រំបន្ទុំចិត្ត ដែលចុងក្រោយក៏ឈានទៅដល់ការត្រាស់ដឹង ។

## ពុទ្ធសាសនានៅប្រទេសចិន

ព្រះពុទ្ធសាសនាបានមានអានុភាពដ៏សំខាន់មួយ យូរអង្វែងមកហើយ ក្នុងការបង្កើតទ្រង់ទ្រាយវប្បធម៌របស់ប្រជាជននៅអាស៊ី ។ ឧទាហរណ៍: ហេតុអ្វីបានជាប្រជាជនចិនជ្រើសរើសយកព្រះពុទ្ធសាសនា ប្រសើរជាងសាសនាដទៃមាននៅក្នុងប្រទេសឥណ្ឌា ដូចជាសាសនាព្រាហ្មណ៍ និងសាសនាជេនជាដើម?

ពួកគេ (ប្រជាជនចិន) មានជំនឿផ្ទាល់របស់គេ នៅក្នុងប្រទេសចិនស្រាប់ហើយ តែពួកគេមិនពេញចិត្ត ។ ពួកគេចង់រកឃើញនូវចម្លើយចំពោះបញ្ហាចោទជាច្រើនអំពីជីវិត ប៉ុន្តែពួកគេមិនអាចរកចម្លើយទាំងនោះ នៅក្នុងសាសនាផ្សេងៗ មាននៅក្នុងប្រទេសចិន នាសម័យនោះទេ ។

ម្ល៉ោះហើយពួកគេបានទទួលរងនូវការឈឺចាប់ និងបញ្ហា

លំបាកជាច្រើនដើម្បីទៅដល់ប្រទេសឥណ្ឌា ។ ដោយធ្វើដំណើរឆ្លងកាត់តាមស្ទឹង បត់បែនតាមព្រៃ និងតាមវាលខ្សាច់។ ពួកគេបានប្រើរយៈពេលដ៏យូរ ដើម្បីបានទៅដល់ប្រទេសឥណ្ឌា ។

ប៉ុន្តែ ពួកគេមានចិត្តមុតមាំ ក្នុងការស្នាក់នៅទីនោះ ដើម្បីសិក្សាពីព្រះពុទ្ធសាសនា ។ នេះគឺមកពីពួកគេសង្កេតមើលដោយល្អិតល្អន់ រួចពួកគេបានដឹងថា ព្រះពុទ្ធសាសនានោះទើបជាសាសនាមួយជាសាកល ។ គេដឹងថា វាមានលក្ខណៈងាយស្រួល ក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះសាសនានេះ មិនចាំបាច់ធ្វើឲ្យប្រទេសពួកគេ ផ្លាស់ប្តូរនូវរបៀបជីវិតរបស់ប្រជាជនចិនផងខ្លួន ដែលដូនតារបស់គេបានបន្សល់ទុកឲ្យជាងរាប់ពាន់ឆ្នាំ មកហើយនោះ ។ ដោយឃើញតម្លៃដូចនេះពួកគេក៏បានជ្រើសរើសយកព្រះពុទ្ធសាសនាទៅ ។ បន្ទាប់ពីព្រះពុទ្ធសាសនាបានត្រូវនាំចូលក្នុងប្រទេសចិនមក សាសនានេះបានរីកចម្រើន និងត្រូវបានពង្រីងថែមទៀតក្នុងយុគសម័យអាណាចក្រ **ម៉ិង ឆី** ។ ព្រះពុទ្ធសាសនាបានត្រូវប្រកាសជាសាសនារបស់រដ្ឋ នៅក្នុងប្រទេសចិនទៀតផង ។ ប្រទេសចិនបានកត់សំគាល់ឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់មិនបានផ្តុចដំណើរប្រជាជនចិនមិនឲ្យគោរពនូវវប្បធម៌ និងប្រពៃណីរបស់

ខ្លួនទេ ប្រសិនបើវប្បធម៌ប្រពៃណីទាំងនោះមានប្រយោជន៍ ។ អាស្រ័យហេតុនេះហើយ ទើបពួកគេទទួលយកព្រះពុទ្ធសាសនាទៅប្រតិបត្តិ ថែមទាំងបានលើកតម្កើងវប្បធម៌គេទៀតផង ។

ជាលទ្ធផលនាំមកនូវវប្បធម៌ថ្មីមួយ បែបពុទ្ធនិយម ដោយផ្អែកលើទស្សនៈរបស់ប្រជាជនចិន និងពុទ្ធសាសនិក ។

បច្ចុប្បន្ន សាសនានេះត្រូវបានហៅថា ជាសាសនារបស់ចិន ។ ពុទ្ធសាសនាប្រហែលមិនអាចក្លាយជាសាសនាពិភពលោកបានទេ ប្រសិនប្រជាជនចិនមិនទទួលយកទេនោះ ។

នៅពេលដែលពុទ្ធសាសនា បានមកដល់ប្រទេសចិន ហើយសាសនានេះមិនបាននៅតែមួយកន្លែងក្នុងទីនោះទេ ។ គឺប្រជាជនចិនបាននាំពុទ្ធសាសនាទៅផ្សព្វផ្សាយនៅកូរ៉េ ។ ហើយប្រទេសកូរ៉េបាននាំទៅផ្សព្វផ្សាយ ដល់ប្រទេសជប៉ុនទៀតផង ដោយបានដើរតួជាកម្លាំងអរិយធម៌-វប្បធម៌មួយដ៏អស្ចារ្យ។

## ពុទ្ធសាសនានៅម៉ាឡេស៊ី

ឥឡូវសូមយើងក្រឡេកមើលប្រទេសម៉ាឡេស៊ីវិញម្តង ។ ប្រទេសម៉ាឡេស៊ីជាប្រទេសមួយបានកាន់ពុទ្ធសាសនា រហូតដល់សតវត្សរ៍ទី១៤ នៅពេលដែលអាណាចក្រ **ស្រីវិជ័យ** មាន

ឥទ្ធិពលនៅក្នុងប្រទេសឥណ្ឌូនេស៊ី ។ ពេលនោះមេដឹងនាំពួកមូស្លីម (ឥស្លាមសាសនិក) នៅទីក្រុងម៉ាលាស់ស្កា នៅកាន់សាសនាឥស្លាមនៅឡើយ ។

បន្ទាប់មក ប្រទេសទាំងមូលក៏ក្លាយជាឥស្លាមសាសនិកប្រទេស។

លុះដល់រយៈពេល ៦០០ ឆ្នាំក្រោយមក កេរ្តិ៍ឈ្មោះព្រះពុទ្ធសាសនាក៏បានបាត់ចេញពីប្រទេសនេះទៀត ។

ទោះជាយ៉ាងនេះក្តី នៅពេលដែលជនជាតិចិនបានផ្លាស់លំនៅមកនៅប្រទេសនេះ នៅចុងសតវត្សរ៍ទី ១៩ និងដើមសតវត្សរ៍ទី ២០ បែបផែនជីវិតនៃពុទ្ធសាសនិកបានត្រូវនាំចូលមកក្នុងប្រទេសម៉ាឡេស៊ីសាជាថ្មី ។ ក្រោយមក ប្រទេសស្រីលង្កា ថៃ និងមីយ៉ាន់ម៉ា បានផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹង ដើម្បីលើកស្ទួយវិស័យព្រះពុទ្ធសាសនានៅក្នុងប្រទេសម៉ាឡេស៊ី ។

បច្ចុប្បន្ន ប្រជាជន ១៨% នៅក្នុងប្រទេសនេះ ជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយបានធ្វើឲ្យសាសនានេះ ទៅជាសាសនាចម្បងទី ២ ទៀតផង ។

ព្រះពុទ្ធសាសនា បានត្រូវធ្វើឲ្យរស់រានមានជីវិតឡើងវិញ

នៅក្នុងប្រទេសម៉ាឡេស៊ី ដោយសារជនជាតិចិន ។

គេត្រូវចាំថា គឺដូនតាពួកគេទេ ដែលបានទទួលខុសត្រូវចំពោះការនាំមកនូវសាសនាដ៏ប្រសើរនេះមកវិញ។ ដូច្នេះហើយ វាជាបន្ទុកភារកិច្ច របស់អនុជនដើម្បីរក្សាទុកនូវសាសនានេះ សម្រាប់ជាមាគ៌ាជីវិតរបស់ខ្លួន ។ ជាសាសនាដែលជាប់ទាក់ទិនយ៉ាងជិតស្និទ្ធជាមួយនឹងវប្បធម៌ និងចិត្តគំនិតរបស់គេ ។ សព្វថ្ងៃនេះ ពួកគេលះបង់សាសនានេះចោលដើម្បីលាភសក្ការៈ និងព្រោះហេតុផលខាងផ្លូវចិត្ត ដែលខ្វះវិចារណញ្ញាណ ។

បច្ចុប្បន្ននេះ ក្នុងនាមនៃការផ្លាស់ប្តូរជំនឿ និងការសង្គ្រោះ ក៏មានអ្នកកាន់សាសនាមួយចំនួន ទិញទឹកចិត្តរបស់មនុស្ស ។ ពួកគេមានបំណង ដើម្បីចំណាយ និងផ្តល់នូវវត្ថុសម្ភារៈឲ្យដល់ជនទាំងនោះ ។

ពុទ្ធសាសនិកមិនគប្បីបោះបង់សាសនាដ៏ប្រសើរនេះ ព្រោះតែរឿងលាភសក្ការៈទេ ។ បន្ទាប់ពីការផ្លាស់ប្តូរមក មេរៀនដំបូងដែលអ្នកដឹងនាំសាសនាទាំងនេះ ណែនាំនោះគឺការស្អប់ ។ ដោយបង្ខំឲ្យមានការផ្លាស់ប្តូរជំនឿថ្មី ដើម្បីបំផ្លាញនូវសរណវត្ថុនានារបស់សាសនា ដែលពួកគេបានគោរពបូជា ព្រមទាំងដូនតារបស់គេ ក៏បានធ្វើសក្ការបូជាអស់ជាច្រើន ជំនាន់មកហើយ

ដែរ ។ នៅក្នុងប្រវត្តិសាស្ត្រទាំងអស់របស់ខ្លួន (របស់ប្រទេសម៉ាឡេស៊ី) មិនដែលមានកំណត់ហេតុណាមួយនិយាយអំពីពុទ្ធសាសនិកជនអនុវត្តនូវការបំផ្លិចបំផ្លាញនូវសរណវត្ថុទាំងឡាយរបស់សាសនាយ៉ាងនេះទេ ។

## ទស្សនាទានរបស់អ្នកប្រែរៀបរៀង

ប្រជាជននៅក្នុងប្រទេសកម្ពុជាយើង ក៏ជាអ្នកគោរពជឿកាន់ព្រះពុទ្ធសាសនាយ៉ាងហ្មត់ចត់ តាំងពីបុរាណកាលរៀងមកដែរ ។ រហូតមកដល់បច្ចុប្បន្ននេះឈានចូលដល់សតវត្សរ៍ទី ២១ ដែលជាសម័យវិទ្យាសាស្ត្រ កំពុងមានការរីកចម្រើនជុះជាលលើគ្រប់វិស័យក៏ដោយ ក៏ព្រះពុទ្ធសាសនានៅតែដើរតួនាទីជាជំនួយយ៉ាងសំខាន់ដល់សង្គមដដែល ។ វិទ្យាសាស្ត្រមិនអាចខ្វះសាសនាបានទេ ប្រៀបដូចអាខ្វាក់អាខ្វិន ដូច្នោះឯង ។ ដូច្នេះ សាសនាពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានមែន ជាពិសេសគឺ ព្រះពុទ្ធសាសនាហ្នឹងតែម្តង ។

ដូចដែលយើងដឹងស្រាប់ហើយថា នៅក្នុងសម័យដែលប្រទេសខ្មែរយើងមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល ប្រពៃណីទំនៀមទម្លាប់ វប្បធម៌ អក្សរសាស្ត្រ វិស័យអប់រំ និងវិស័យ

ផ្សេងៗទៀត ស្ទើរតែគ្រប់ផ្នែកទាំងអស់នៅក្នុងប្រទេស បានរត់មកជ្រកកោន ក្នុងវត្តអារាមក្រោមម្លប់ដំបូលព្រះពុទ្ធសាសនា ហើយបានស្ថិតនៅគង់វង្សជាប្រយោជន៍ដល់យើងគ្រប់គ្នា បានស្គាល់ចេះដឹងរហូតដល់សព្វថ្ងៃនេះ ក៏ដូចជាទៅក្នុងថ្ងៃអនាគតទៀត ។ ដូចនេះ ក្នុងនាមយើងជាពុទ្ធសាសនិក គប្បីរក្សាបវេណីដ៏ល្អនេះ ឲ្យបានខ្ជាប់ខ្ជួន មិនត្រូវបោះបង់ពុទ្ធសាសនាដែលជាសាសនារបស់ជាតិយើងទេ ព្រោះប្រទេសយើងបានកំណត់យកពាក្យ "ជាតិ សាសនា ព្រះមហាក្សត្រ" ជាបាវចនារបស់ជាតិ ។ បើយើងបោះបង់សាសនារបស់យើងចោល ហើយងាកទៅកាន់ជឿសាសនាដទៃ នោះឈ្មោះថា យើងបដិសេធបាវចនាជាតិ របស់ខ្លួនឯងមួយគឺ "សាសនា" នេះឯង ។

មានអ្នកខ្លះ ក្បត់នឹងឧត្តមគតិខ្លួនឯង គឺចូលទៅក្នុងសមាគមសាសនាដទៃហើយ តែនៅយកព្រះពុទ្ធសាសនា ធ្វើជារនាំង ឬរនាំងបិទបាំងនូវ អំពើអាក្រក់របស់ខ្លួនខ្លះ បំពេញសំណុំបែបបទពាក្យធ្វើការងារដាក់ថា កាន់សាសនាព្រះពុទ្ធ ប៉ុន្តែតាមពិត ព្រះពុទ្ធតែនៅលើក្រដាសប្រវត្តិរូបសោះ ឯចិត្តគេនៅក្នុងព្រះយេហូវ៉ា ព្រះអាឡាហ៍ឯណោះ ជាព្រះនៅលើឋានសួគ៌ មិនទាំងដែលឃើញស្រមោលផង តែជឿងប់ងល់ ។

ជូនតាមរយៈការសិក្សាមកបានប្រាប់ឲ្យដឹងថា សាសនាទាំង-ឡាយនៅក្នុងលោក រួមមាន សាសនាព្រាហ្មណ៍ សាសនាគ្រិស្ត សាសនាឥស្លាម ជាដើម ។ សាសនាទាំង ៣ នេះ គ្មានហេតុផលច្បាស់លាស់ទេ គឺពួកគេបានបដិសេធចោលទ្រឹស្តី "កម្ម" ដែលជាហេតុ ជាពូជ ហើយទៅយកព្រះ យកទេវតា យកអាទិទេព មកធ្វើជាហេតុ ជាពូជទៅវិញ ដល់កើតផលមកឃើញថា ផ្ទុយគ្នាខុសពីពូជស្រឡះ គឺពូជជាព្រះ ជាទេវតា កើតផលទៅជាមនុស្ស សត្វ ដី ទឹក ភ្លើង ខ្យល់ ព្រៃព្រឹក្សា លតាវល្លិ៍ទៅវិញ ។តាមពិត សាសនាទាំងនេះ មានតែវិធីសាស្ត្រ និងនិទស្សនៈប៉ុណ្ណោះ ហើយថែមទាំងខ្វះហេតុ ផលត្រឹមត្រូវទៀត មិនដូចខាងពុទ្ធសាសនាឡើយ ។ ព្រះពុទ្ធសាសនាជាសាសនាដែលមានហេតុផលត្រឹមត្រូវ ដូចបទបាលីថា៖ "**យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ កល្យាណការី កល្យាណំ បាបការី ច បាបកំ**" ប្រែថា បុគ្គលណាមួយសាបព្រោះបណ្តុះនូវពូជដំណាំណា រមែងតែងតែបានផលអំពីដំណាំនោះវិញ ពុំដែលប្រែក្លាយចាកអំពីពូជដើមឡើយ ។ បើបុគ្គលសាបព្រោះស្រូវ រមែងបានផលគឺផ្លែស្រូវវិញ សាបព្រោះបណ្តុះសណ្តែក រមែងបានផលជាសណ្តែកវិញ យ៉ាងណាមិញ

វីអំពើបុណ្យ និងបាបក៏យ៉ាងនោះដែរ ។ គាថាប៉ុណ្ណោះបញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាពិតជាមានហេតុផលត្រឹមត្រូវមែន ។

ដូចនេះ យើងជាប្រជាជនខ្មែរទាំងអស់ ត្រូវតែពង្រឹងពង្រីកព្រះពុទ្ធសាសនា ត្រូវតែដឹងគុណ តបគុណ គោរពលើកតម្កើង និងថែរក្សាការពារព្រះពុទ្ធសាសនា ដែលជាសាសនារបស់ខ្លួនស្មើជីវិត មិនត្រូវវង្វេងសាសនា បម្រើមនោគមវិជ្ជាបរទេស ។ យើងមិនត្រូវបោះបង់សាសនាយើង ព្រោះតែរឿងលាភសក្ការៈវត្ថុ និងអំណោយបន្តិចបន្តួច តាមរយៈការទិញទឹកចិត្តពីសំណាក់អ្នកកាន់ និងអ្នកផ្សព្វផ្សាយសាសនាដទៃឡើយ ។ យើងត្រូវមានហេតុផលខាងផ្លូវចិត្តប្រកបដោយវិចារណញ្ញាណត្រឹមត្រូវ មុននឹងធ្វើនូវអ្វីៗ ។ បើមិនអឺចឹងទេ មិនខុសអ្វីនឹងការបោះបង់ចោលដុំពេជ្រ ហើយទៅស្រវាយកដុំគ្រួសនោះឡើយ។ បច្ចុប្បន្ននេះ សាសនាដទៃកំពុងតែជ្រៀតជ្រែក ចូលក្នុងសង្គមខ្មែរយើង ក្រោមរូបភាពផ្សេងៗ ។ ដូច្នេះ កូនខ្មែរគ្រប់រូបត្រូវតែប្រយ័ត្ន ពុំនោះទេ យើងនឹងមានគ្រោះថ្នាក់ខាងជំនឿសាសនាហើយ ។ ថ្វីត្បិតតែច្បាប់រដ្ឋធម្មនុញ្ញប្រទេសយើងបានចែងអំពីសិទ្ធិសេរីភាពខាងជំនឿសាសនាមែន ប៉ុន្តែយើងត្រូវយល់ដឹងត្រូវគិត ឲ្យបានល្អិតល្អន់អំពីបញ្ហានេះ ។ កុំចង់បានផលតូច

បន្ទុចផលធំ ។ បើយើងលក់ ឬបោះបង់ព្រលឹងយើងឲ្យគេទៅហើយ តើជីវិតយើងរស់នៅ មានន័យអ្វីទៀត?

## សាសនាដែលពួកបញ្ញវន្តអាចឲ្យតម្លៃ

ព្រះពុទ្ធសាសនាគឺជាសាសនាមួយដ៏ប្រសើរបំផុត ដែលជាសាសនាត្រូវបានឲ្យតម្លៃពីសំណាក់ពួកបញ្ញវន្តអ្នកវិទ្យាសាស្ត្រ អ្នកប្រើគំនិតថ្មីៗ អ្នកទស្សនវិជ្ជា អ្នកសនិទាននិយម (អ្នកនិយមខាងហេតុសមស្រប) និងថែមទាំងអ្នកគិតសេរី នៅទូទាំងពិភពលោក ។ ព្រះពុទ្ធទ្រង់ត្រាស់ថា “ធម៌ដែលតថាគតសំដែង គឺអាចមានតែពួកជនដែលដឹងពីរបៀបគិតប្រកបដោយបញ្ញា ។ ឯបុគ្គលទុប្បញ្ញាវិញ មិនដឹងពីរបៀបឲ្យតម្លៃដល់ធម៌នេះទេ” ។

បុគ្គលជាបញ្ញវន្ត ដែលមានប្រាជ្ញាចេះប្រើប្រាស់ចិត្តរបស់គេបានច្បាស់លាស់ និងឲ្យតម្លៃទៅលើធម៌នេះថា ជាច្បាប់សាកលមួយ ។ អ្នកវិទ្យាសាស្ត្រនានាបានរកឃើញនូវរបស់ជាច្រើន ជាង ១០០ ឆ្នាំកន្លងមកហើយ ឯរបកគំហើញទាំងឡាយរបស់គេនោះ បានធ្វើការប្រកួតប្រជែងទៅនឹងច្បាប់បញ្ញត្តិរបស់សាសនាមួយចំនួន ។ ប៉ុន្តែអ្នកវិទ្យាសាស្ត្រមិនអាចរកឃើញ

អ្វីមួយ ដែលផ្ទុយនឹងធម្មសាស្ត្រ ឬច្បាប់បញ្ញត្តិរបស់ព្រះពុទ្ធឡើយ ។

ពួកគេរកឃើញពីអាថ៌កំបាំងរបស់សកលលោក កាន់តែច្រើនឡើង តែក៏រឹតតែខិតមកជិតព្រះពុទ្ធសាសនា កាន់តែច្រើនដែរ ។ លោក ហ. ហ្គ. វែលស៍ ជាអ្នកប្រវត្តិសាស្ត្រពិភពលោកមួយរូបនិយាយថា: នៅក្នុងសៀវភៅរបស់គាត់មួយក្បាល ក្នុងចំណោមសៀវភៅជាច្រើនក្បាល នៅពេលយើងសិក្សាគម្ពីរនោះទៅ វាប្រាប់យើងឲ្យដឹងថា អាទិទេពបង្កើតលោកនេះ ៦០០០ ឆ្នាំកន្លងមកហើយ ។

តែនៅពេលយើងសិក្សា ផ្នែកភូគព្ភសាស្ត្រវិញ យើងអាចដឹងថា វាបានកើតឡើងរាប់សិបកោដិឆ្នាំ ចំពោះភពផែនដីដែលដុះឡើង និងតាំងនៅមុនពេលភាវរស់កើតមានទៅទៀត ។

ម្ល៉ោះហើយ តើយើងអាចជឿនូវអ្វីដែលគេសរសេរក្នុងគម្ពីរព្រះ (គម្ពីរខាងសាសនាគ្រិស្ត) របស់យើងម៉េចនឹងកើតទៅ?

## ឥរិយាបថរបស់សាសនាមួយចំនួន

ច្បាប់អាជ្ញារបស់សាសនាមួយចំនួន ណែនាំសាវករបស់ពួកគេ មិនឲ្យស្តាប់ការសន្ទនាធម៌របស់សាសនាដទៃ មិនឲ្យ

អានសៀវភៅសាសនាដទៃ និងមិនឲ្យឈានជើងចូលទៅទីកន្លែងធ្វើសក្ការបូជារបស់សាសនាដទៃទេ ។ គេគម្រាមថា ប្រសិនបើសាវ័ក ឬបរិស័ទទាំងនោះ ធ្វើដូចនេះ ព្រះអាទិទេពរបស់គេនឹងខឹង ហើយដាក់ទោសដល់ពួកគេ ។

នេះជាវិធីដែលគេបិទភ្នែកបរិស័ទរបស់ពួកគេ និងទុកឲ្យបរិស័ទទាំងនោះ ស្ថិតនៅក្នុងសេចក្តីភ័យខ្លាច និងអវិជ្ជា ។ ហេតុអ្វីគេណែនាំក្នុងរបៀបនេះទៅវិញ?

ប្រសិនបើជនទាំងឡាយ ត្រូវបានអនុញ្ញាតឲ្យស្តាប់ការនិយាយធម៌របស់សាសនាដទៃ អានគម្ពីរធម៌សាសនាដទៃ និងទៅទស្សនាកន្លែងសក្ការបូជាសាសនាទាំងនោះទៅ អ្នកដឹកនាំទាំងនោះខ្លាចក្រែងថា ជំនឿដែលគេសំដែងទុក អាចត្រូវបានគេបោះបង់ចោល នៅពេលដែលជនទាំងឡាយនោះបើកចិត្តទូលាយរបស់គេ ដើម្បីស្តាប់អ្នកដទៃ ។

ហេតុនេះសាវ័ក ឬបរិស័ទទាំងឡាយនោះ មិនត្រូវបានអនុញ្ញាតឲ្យបើកចិត្តរបស់ខ្លួនទូលំទូលាយបានទេ។ ផ្ទុយទៅវិញ គេបានទុកឲ្យបរិស័ទទាំងនោះ កាន់ជំនឿរបស់គេទាំងងងឹតងងល់ ។ បុរសខ្លាំងមិនត្រូវខ្លាច សត្រូវរបស់ខ្លួនទេ ។

## របៀបរស់នៅតាមបែបសាសនា ប្រកបដោយវិចារណញ្ញាណ

ផ្ទុយទៅវិញ ព្រះសម្មាសម្ពុទ្ធទ្រង់បានលើកទឹកចិត្តដល់សាវ័ករបស់ព្រះអង្គឲ្យសិក្សា ឲ្យចេះសង្កេតពីរបៀប ដែលជនទាំងឡាយប្រតិបត្តិ នូវសាសនាទាំងឡាយផ្សេងៗគ្នា ដោយខ្លួនគេ ។

នៅបស្ចិមប្រទេស ឈ្មោះថ្មីដែលគេប្រសិទ្ធិនាម ឲ្យដល់ព្រះពុទ្ធសាសនានោះគឺ “សាសនាប្រកបដោយសិទ្ធិសេរីភាព និងហេតុផល” ។ តាំងពីនោះមក ពុទ្ធសាសនិកទាំងឡាយមិនពឹងពាក់លើអាទិទេព ដើម្បីការសង្គ្រោះដល់ខ្លួនពួកគេទៀតទេ ប៉ុន្តែត្រូវបានជម្រុញឲ្យជុសខាត់ ជម្រះចិត្តរបស់ខ្លួនគេផ្ទាល់ទៅវិញ ។

ព្រះពុទ្ធសាសនា ក៏ត្រូវបានបញ្ញត្តិថាជា “សាសនាមួយធ្វើអ្វីៗ ដោយខ្លួនឯង” (ឬផ្អែកលើបទបាលីមួយឃ្លាថា អត្តាហិ អត្តនោ នាថោ: ប្រែថា ខ្លួនជាទីពឹង របស់ខ្លួន ។

ជាក់ស្តែង ព្រះពុទ្ធសាសនាជាសាសនាមួយ សម្រាប់ភាពបរិសុទ្ធខាងប្រាជ្ញាស្មារតី ។

ប្រជាជននៅក្នុងប្រទេសលោកខាងលិចនិយាយថា: ពួកគេមិនអាចរកឃើញនូវគុណភាពទាំងពីរ (សិទ្ធិសេរីភាព និងហេតុ

ផល) នេះនៅក្នុងសាសនាណាមួយទេ ប៉ុន្តែមានតែនៅក្នុងសាសនាព្រះពុទ្ធប៉ុណ្ណោះ ។

ព្រះពុទ្ធមានប្រាថ្នា ដើម្បីរំដោះយើងឲ្យរួចផុតពីទាសភាពខាងសាសនា ។ ដោយណែនាំពីសាសនាមួយ ប្រកបដោយហេតុផល សម្រាប់យើងប្រតិបត្តិ ។ ដោយផ្ដល់នូវប័ណ្ណដ៏សមរម្យ ទៅតាមបញ្ញានៃមនុស្សយើង និងរក្សាបាននូវសេចក្ដីថ្លៃថ្នូរ របស់មនុស្សយើងថែមទៀតផង ។

មានពុទ្ធសាសនា យើងអាចបណ្ដុះនូវតម្លៃរបស់មនុស្សយើង ដោយមិនចាំបាច់មានបញ្ញា ច្បាប់សាសនា និងការដាក់ទោស របស់សាសនានានាឡើយ ។

នៅពេលដែលយើងចាប់សត្វព្រៃទាំងឡាយដូចជា គោ ខ្លាជាដើម យើងបន្ទ្រាំងសត្វនោះ ដោយការវាយ និងការបង្កើតសេចក្ដីភ័យខ្លាចក្នុងខ្លួនវា ។ បន្ទាប់មកវាធ្វើតាមយើង វាស្ដាប់យើង ប៉ុន្តែវាគ្មានវិចារណញ្ញាណ ប្រកបដោយហេតុផលទេ ។

ប្រសិនបើសត្វនោះ ត្រូវបានគេលែងឲ្យវិលទៅរកសភាពដើមតាមធម្មជាតិវិញ សភាវគតិរបស់វា ក៏វិលត្រឡប់មករកភាពដើមវិញដែរ ។ ហើយវាថែមទាំងអាចវាយបកមកលើម្ចាស់វាវិញដោយពិត ។ ដោយសារសេចក្ដីភ័យខ្លាច វាមិន

អាចទាន់ហ៊ានធ្វើបាបអ្នកដទៃទេ ។

ជនទាំងឡាយណា ដែលកាន់ច្បាប់សាសនាដូចហេតុបានរៀបរាប់មកនេះ អាចប្រៀបប្រដូចទៅនឹងសត្វទាំងនោះ ដែលមិនហ៊ានធ្វើបាបអ្នកដទៃ ព្រោះតែសេចក្ដីភ័យខ្លាច និងការដាក់ទោសទណ្ឌកម្មដូច្នោះឯង ។ ព្រះសម្មាសម្ពុទ្ធមិនដែលខ្លាចសាសនាដទៃទេ ។ ព្រះអង្គបានត្រៀមខ្លួនទទួលស្គាល់ នូវការពិត ប្រសិនបើសាសនានោះបានត្រូវរកឃើញនៅក្នុងធម្ម-សាស្ត្រណាមួយ ។

តាមពិតព្រះអង្គទ្រង់បានលើកទឹកចិត្តដល់សាវ័កទាំងឡាយឲ្យចេះគោរពគ្រូដទៃៗ ។ នៅថ្ងៃមួយមានសេដ្ឋីម្នាក់មិនមែនជាពុទ្ធសាសនិកបានមកគាល់ព្រះសម្ពុទ្ធ ហើយទូលព្រះអង្គថាគាត់ចង់ក្លាយជាពុទ្ធសាសនិកម្នាក់ ។ គាត់បាននិយាយថា "ទូលបង្គំបានស្ដាប់ព្រះធម៌ របស់ព្រះអង្គល្អណាស់ ។ ម្ល៉ោះហើយ ទូលបង្គំក៏បានសម្រេចចិត្ត ចង់ក្លាយជាពុទ្ធសាសនិកមួយរូប" ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សួរថា៖ "តើអ្នកបានព្រះធម៌របស់តថាគតឬ?" គាត់ឆ្លើយថា "ទេ" ។ ព្រះអង្គត្រាស់សួរទៀតថា "អ្នកដឹងទេថា តើអ្នកអាចប្រតិបត្តិធម៌របស់តថាគតបានដែរ ឬអត់?" បុរសនោះឆ្លើយថា "ទេ" ។ ព្រះសម្មាសម្ពុទ្ធ

ទ្រង់បានត្រាស់ថា “នោះមិនមែនជាផ្លូវកាន់សាសនាមួយទេ!” ព្រះពុទ្ធបានត្រាស់ទៀតថា៖ “ដំបូងអ្នកត្រូវសង្កេតមើលថា តើអ្នកអាចប្រតិបត្តិនូវសាសនាថ្មីបានដែរ ឬយ៉ាងណា?” បន្ទាប់មកសេដ្ឋីនោះនិយាយថា “ទូលបង្គំគិតថា ឱវាទនេះផ្ដល់គឺមានសភាពគ្រប់គ្រាន់ សម្រាប់ទូលបង្គំ ដើម្បីយល់នូវធម្មជាតិនៃច្បាប់បញ្ញត្តិ របស់ព្រះអង្គហើយ” ។

ប្រសិនបើទូលបង្គំទិតជិតគ្រូសាសនាដទៃ ពេលនោះគ្រូនោះឯងបានបង្ខំទូលបង្គំឲ្យជឿតាម ហើយក៏ប្រកាសរឿងនោះទៅឲ្យអ្នកដទៃដឹងឮ ។

ផ្ទុយទៅវិញ ព្រះអង្គបានទូន្មានទូលបង្គំ ឲ្យរង់ចាំសិក្សាសង្កេតមើលសិន ទើបឲ្យសម្រេចចិត្តដោយប្រុងប្រយ័ត្ន ។ ទូលបង្គំពេញចិត្តណាស់ ។ ឥឡូវទូលបង្គំត្រូវបានធ្វើឲ្យជាក់ច្បាស់ ។ ទូលបង្គំចង់ធ្វើជាពុទ្ធសាសនិកមួយរូបមែន!

បន្ទាប់មកគាត់ក៏បានចាប់ផ្ដើមសួរទៀតថា “ទូលបង្គំបាននិងកំពុងទំនុកបម្រុងដល់បព្វជិត ក្នុងសាសនាដើមរបស់ទូលបង្គំ ដែលឥឡូវនេះជាពុទ្ធសាសនិក តើទូលបង្គំនៅអាចទំនុកបម្រុងដល់បព្វជិតនោះទៀតបានដែរឬទេ?”

ព្រះពុទ្ធទ្រង់បានត្រាស់ថា “អ្នកអាចឧបត្ថម្ភដល់ជនណា

មួយក៏បាន ព្រោះនេះជាអំពើបុណ្យ” ។

សូមសង្កេតមើល ពីរបៀបឥរិយាបថនេះគឺខុសគ្នាពីឥរិយាបថរបស់សាសនាមួយចំនួន ដែលយើងឃើញសព្វថ្ងៃនេះ ។

នៅពេលអ្នកកាន់សាសនារបស់យើងសុំអំណោយ ពីអ្នកកាន់សាសនាដទៃ, គេនិយាយថា “សូមទោសយើងមិនអាចឲ្យអំណោយទាំងនេះ ទៅឲ្យសាសនាផ្សេងបានទេ ។ ព្រោះវាជួយនឹងសាសនារបស់ពួកយើង ហើយយ៉ាងណាមិញក៏ជាអំពើបាបមួយផង” ។

ជួយគ្នាទៅនឹងឥរិយាបថនេះ ដែលការពិតនៅត្រង់ថា អ្នកផ្តល់ជំនួយទៅឲ្យអង្គការវិភាគទានមួយចំនួនធំ ដែលមិនមែនជាពុទ្ធសាសនិក នៅក្នុងប្រទេសម៉ាឡេស៊ី គឺជាពុទ្ធសាសនិកទៅវិញ ។

នេះគឺគ្រាន់តែជាហេតុផលមួយ ដែលពួកបញ្ញវន្តនិយាយថា ព្រះពុទ្ធសាសនា គឺជាសាសនាមួយប្រកបដោយសិទ្ធិសេរីភាព និងហេតុផលនោះ ។

# ពុទ្ធសាសនា និងបច្ចេកវិទ្យាទំនើប

នៅទូទាំងពិភពលោក ប្រជាជនទាំងឡាយកំពុងព្យាយាម ប្រកាន់យក នូវផែនការគ្រួសារ ហើយសាសនាមួយចំនួន ជាកម្មវត្ថុរបស់ផែនការនោះ ។

ពួកគេនិយាយថា កូនទាំងឡាយគឺជាអំណោយរបស់អាទិទេព ប្រសិនបើអាទិទេពឲ្យ យើងត្រូវតែទទួលយក ។ ហេតុអ្វីចាំបាច់ដាក់សាសនាបញ្ចូល ក្នុងផែនការគ្រួសារនេះ?

សាសនាគ្មានអ្វីពាក់ព័ន្ធជាមួយនឹង សកម្មភាពនៃសង្គមបែបនេះទេ ។ ប្រសិនយើងពឹងផ្អែកលើគម្ពីរពិសិដ្ឋ (គម្ពីរសាសនាយេស៊ូ) គ្រប់យ៉ាង ដោយមិនប្រើសុភវិនិច្ឆ័យរបស់យើងទេនោះ យើងអាចធ្លាក់ក្នុងបញ្ហា ។ ខ្ញុំសូមលើកយករឿងមួយមកអធិប្បាយដូចតទៅនេះ៖

កាលកន្លងទៅហើយ មានគ្រូបង្រៀនខាងសាសនាម្នាក់ មានអន្តេវាសិក (កូនសិស្ស) ពីរបីពាន់នាក់ ។ គ្រូនោះហ្មត់ចត់ណាស់ ហើយបាននិយាយចចេសថា ពាក្យសម្តីរបស់លោកគឺជាច្បាប់ ។

លោកបានសរសេរទុកនូវការបង្រៀនទាំងអស់ នៅក្នុងគម្ពីរស័ក្តិសិទ្ធិរបស់លោក ហើយព្រមានកូនសិស្សរបស់លោក

កុំឲ្យធ្វើអ្វីៗ ដោយមិនបានសំអាងលើគម្ពីរនោះ ។

ថ្ងៃមួយពេលដែលគ្រូនេះ និងអន្តេវាសិករបស់ខ្លួន កំពុងដើរឆ្លងកាត់ស្ពានតូចចង្អៀតមួយ គ្រូនោះក៏រអិលធ្លាក់ទៅក្នុងស្ទឹង ។

កូនសិស្សទាំងឡាយ ក៏ចាំបាននូវការបង្រៀនរបស់គ្រូ ហើយចង់អានគម្ពីរស័ក្តិសិទ្ធិនោះ ដើម្បីកំណត់ដឹង នូវអ្វីដែលលោកបានបញ្ញត្តិ និងអ្វីដែលលោកអនុញ្ញាតឲ្យធ្វើ នៅពេលដែលគ្រូធ្លាក់ចូលទៅក្នុងទឹកដូច្នោះ ។ គ្រូនោះ ក៏បានស្រែកហៅឲ្យជួយ ប៉ុន្តែអន្តេវាសិកទាំងឡាយនិយាយគ្នាថា "ចាំបន្តិចសិនៗ ពួកយើងចង់ដឹងនូវអ្វី ដែលលោកគ្រូបានសរសេរនៅក្នុងគម្ពីរ របស់យើងអំពីស្ថានភាពបែបនេះ"។

ពិតមែនហើយ គ្រូនោះត្រូវបានលង់ទឹកស្លាប់ មុនពេលដែលពួកគេបានរកឃើញនូវការបង្ហាត់បង្រៀននោះ ។

រឿងដូចគ្នានេះអាចកើតឡើងដល់យើង ប្រសិនបើយើងពឹងពាក់យ៉ាងផងឹតផងល់ លើគម្ពីរស័ក្តិសិទ្ធិរបស់យើងគ្រប់ហេតុការណ៍ ។

ប្រជាជនត្រូវមានសិទ្ធិសេរីភាព ដើម្បីបន្តនូវកិច្ចការគ្រួសាររបស់គេ ស្របតាមប្រាថ្នារបស់ខ្លួនគេ និងអ្វីៗដែលមាន

ប្រយោជន៍បំផុតចំពោះសង្គម និងស្របតាមភាពសមរម្យរបស់ខ្លួនផង ។ គេនឹងមិនធ្វើអំពើអាក្រក់ ដល់បុគ្គលណាមួយដោយទង្វើបែបនេះទេ ។

សៀវភៅគម្ពីរទាំងនេះ បានត្រូវសរសេរជាយូរយារណាស់ហើយ មិនមែនសុទ្ធតែអាចមានចម្លើយត្រូវចំពោះបញ្ហាគ្រប់យ៉ាង ដែលយើងប្រឈមមុខ សព្វថ្ងៃនេះបានទេ ។

ពិតណាស់ អ្នកដឹកនាំសាសនាមួយចំនួនបកប្រែឡើងវិញឲ្យបានសមរម្យនូវគម្ពីររបស់គេ ដើម្បីរក្សាល្បឿនជាមួយនឹងរបកគំហើញផ្នែកវិទ្យាសាស្ត្រទំនើប ដែលពួកគេមិនអាចប្រកែកបានគឺការវិវត្តពិភពដើម របស់ពិភពលោក តួនាទីរបស់ស្ត្រី ការលើកលែងទោសចំពោះអំពើបាប និងវិសមភាព ក្នុងចំណោមមនុស្ស ។

ព្រះពុទ្ធសាសនាពិតជាគ្មានបញ្ហាបែបនេះទេ ព្រោះព្រះពុទ្ធមិនដែលបន្ទឹវាថា អ្វីដែលអ្នកវិទ្យាសាស្ត្រសព្វថ្ងៃ មិនថាពិតនោះទេ ។ ហេតុផលមួយដែលថា ព្រះពុទ្ធសាសនារីកពាលដាលទៅក្នុងពួកបញ្ញវន្តបច្ចុប្បន្ននេះ គឺនៅត្រង់ថា វិធីសាស្ត្ររបស់ព្រះពុទ្ធ គឺជាវិធីសាស្ត្រ ដែលជួយឲ្យវិទ្យាសាស្ត្ររកឃើញនូវការពិតអំពីខ្លួនយើង និងវត្ថុធាតុទាំងឡាយ ។

គួយ៉ាងដូចជាព្រះពុទ្ធ និងអ្នកវិទ្យាសាស្ត្រទាំងឡាយរមែង សង្កេតឃើញនូវអ្វីៗជុំវិញខ្លួនគេ ដោយមិនលំអៀង ក្នុងគោលបំណងដើម្បីឃើញនូវវត្ថុទាំងឡាយ ទៅតាមសភាវៈពិត (យថាភូត) ។

គ្រាន់តែព្រះពុទ្ធ និងអ្នកវិទ្យាសាស្ត្រ មិនត្រូវធ្វើឲ្យស្ញើចសរសើរ ឬធ្វើឲ្យមានឥទ្ធិពល ពីសំណាក់ជំនឿដែលគេកាន់មុនៗប៉ុណ្ណោះ ។

គ្មានបញ្ហាអ្វីដែលតម្រូវ ឲ្យពួកគេគោរពយ៉ាងខ្ពង់ខ្ពស់នោះទេ ។ ព្រះពុទ្ធទ្រង់មិនដែលបានប្រកាន់នូវអ្វីៗ ដែលគេមិនអាចទទួលយក ដោយខ្វះហេតុផល និងបទពិសោធន៍ឡើយ ។ ព្រះពុទ្ធទ្រង់ហៅសាវកទាំងអស់ ឲ្យមក ហើយមើលដោយខ្លួនឯង (ឯហិបស្សិកោ) ។ ហើយមិនឲ្យជឿ ក្នុងជំនឿទាំងងងឹតងងល់ទេ ។

ពុទ្ធសាសនិកទាំងឡាយ មិនត្រូវបានធ្វើឲ្យស្រពិចស្រពិលដោយពលវសទ្ធាដែលរំជើបរំជួលចិត្ត និងបីតិសាសនាឡើយ។ ប៉ុន្តែសង្កេតមើលបាតុភូតទាំងអស់ ដោយស្ងប់ស្ងៀម និងដោយវិចារណញ្ញាណ ។

ព្រះពុទ្ធសាសនាមិនបានលើកទឹកចិត្ត ឲ្យជនទាំងឡាយ ធ្វើ

ជាអ្នកខាតបង់ខាងសាសនាទេ ថែមទាំងមិនឲ្យប្រកាន់ជាតិសាសន៍ និងផ្ដន្ទាទោសដល់សាសនាដទៃៗ ដែលមាននៅសព្វថ្ងៃនេះផង ។

តម្រូវការដំបូងក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា គឺមិនទាន់ឲ្យជឿ ប៉ុន្តែត្រូវមានការយល់ដឹង ។

ក៏ដូចជារបកគំហើញវិទ្យាសាស្ត្រមួយដែរ គឺនរណាក៏អាចសួរបានដោយសេរី នូវសុពលភាព និងនូវអ្វីដែលបានប្រកាសពីរបកគំហើញនោះ ។

ជាលទ្ធផល បើទោះជា ២៥ សតវត្សរ៍ទៀតក៏ដោយ ក៏ពុទ្ធសាសនិក គ្មានបញ្ហាអ្វីត្រូវផ្ទៀងផ្ទាត់ឡើងវិញ ជាមួយរបកគំហើញផ្នែកវិទ្យាសាស្ត្រថ្មីៗនេះដែរ ។ ហើយយើងក៏មិនបានប្រឌិត នូវការប្រកាសទាំងនេះដែរ ។ យើងមានសច្ចពុទ្ធភាសិតនៅក្នុងព្រះសូត្រនានា ដូចជាកាលាមសូត្រ ដើម្បីជាភស្តុតាងថា យើងមិនបានធ្វើការប្រកាសមិនត្រឹមត្រូវ ស្ដីពីកិត្តិគុណរបស់ព្រះពុទ្ធអង្គទេ នាពេលបច្ចុប្បន្ននេះ ។

ពុទ្ធសាសនិកទាំងឡាយ មិនតម្រូវឲ្យសរសេរឡើងវិញនូវច្បាប់បញ្ញត្តិរបស់ព្រះពុទ្ធទេ នៅពេលត្រូវប្រកួតប្រជែងដោយអ្នកវិទ្យាសាស្ត្រ ។

ក៏ប៉ុន្តែច្បាប់បញ្ញត្តិនេះបញ្ជាក់ថា យើងមិនអាចប្រៀបព្រះពុទ្ធសាសនា និងវិទ្យាសាស្ត្របានងាយៗឡើយ ។

ព្រះពុទ្ធសាសនា បានផ្តល់នូវមូលធាតុសំខាន់ដល់វិទ្យាសាស្ត្រ ព្រោះសាសនាបានផ្តល់នូវនិយាមសីលធម៌ ចំពោះជីវិតរបស់យើង ។ ព្រះពុទ្ធសាសនាសង្កត់ធ្ងន់ទៅលើចិត្ត ដូចជាមេត្តា និងករុណា សម្រាប់ជាសេចក្តីខ្វល់ខ្វាយ ដើម្បីបំបាត់នូវសេចក្តីទុក្ខទាំងឡាយរបស់អ្នកដទៃ ។ ដើម្បីរស់នៅក្នុងជីវិតប្រាសចាកទោស រួមមកបញ្ហាទាំងនេះគឺហួសពីការយកចិត្តទុកដាក់របស់វិទ្យាសាស្ត្រដោយពិត ។ សូមគ្រាន់តែជូនជាឧទាហរណ៍ដូចនេះគឺ៖

ពុទ្ធសាសនិកទាំងឡាយ មិនអនុញ្ញាតឲ្យមានការសម្លាប់សត្វ និងការពន្ធតកូន ក៏គ្មានរឿងអ្វីដែលអ្នកវិទ្យាសាស្ត្រ អាចជំទាស់ទៅនឹងតម្រូវការរបស់គេ នៅក្នុងសង្គមទំនើបនេះដែរ ។ ច្បាប់បញ្ញត្តិទាំងឡាយរបស់ព្រះសម្ពុទ្ធ បានប្រាប់យើងច្បាស់អំពីវិសាលភាពនៃសកលលោក ។ ហើយការអភិវឌ្ឍខាងជាតិពន្ធុ ។ អ្នកដឹកនាំសាសនាមួយចំនួន បានទិតជិតរដ្ឋាភិបាលរបស់គេ ដើម្បីរាំងមិនឲ្យមាននូវជាតិពន្ធុនេះ ។ ចុះមតិពុទ្ធសាសនាអំពីពន្ធុកម្ម យ៉ាងដូចម្តេច?

ពុទ្ធសាសនា តែងតែជំរុញឲ្យមនុស្សប្រើប្រាជ្ញារបស់ខ្លួន ។ ហើយព្រះពុទ្ធសាសនា ក៏មិនដែលព្យាយាមដាក់សម្ពាធទៅលើគំហើញ របស់អ្នកវិទ្យាសាស្ត្រទាំងនោះដែរ ។

ប្រសិនបើអ្នកវិទ្យាសាស្ត្រ ធ្វើអ្វីមួយជាគុណវិសេស ហើយមិនមែនជាបញ្ហាអសីលធម៌ទេ យើងគួរទុកឲ្យពួកគេ បន្តធ្វើការស្រាវជ្រាវចុះ ។ ប្រសិនបើអ្នកវិទ្យាសាស្ត្រទាំងឡាយ អាចធ្វើការងារ របស់អាទិទេពបានអ៊ីចឹង មនុស្សគ្មានរឿងអ្វីត្រូវបុះបាញ់អាទិទេពទេ ។ ហើយនៅក្នុងករណីខ្លះ មិនមានអ្នកវិទ្យាសាស្ត្រណា អាចប្រឆាំងនឹងច្បាប់ធម្មជាតិ របស់វត្ថុទាំងឡាយ ដែលព្រះសម្ពុទ្ធទ្រង់ឲ្យឈ្មោះថាធម៌នោះឡើយ ។ ដូច្នេះអ្នកវិទ្យាសាស្ត្រទាំងឡាយ មិនអាចធ្វើហួសព្រះធម៌នេះបានទេ។ ឧទាហរណ៍ៈ មិនមានអ្នកវិទ្យាសាស្ត្រណា អាចធ្វើឲ្យព្រះអាទិត្យ និងព្រះចន្ទ្រវរៈ នៅក្នុងពេលតែមួយបានឡើយ ។

ក្នុងនាមជាពុទ្ធសាសនិក មិនមានហេតុផលអ្វីសម្រាប់យើងដើម្បីជំទាស់ទៅនឹងរបកគំហើញ របស់អ្នកវិទ្យាសាស្ត្រទាំងនោះទេ ។ អ្នកវិទ្យាសាស្ត្រទាំងឡាយ មិនពឹងពាក់លើអាទិទេពឬសាសនាដើម្បីរកអ្វីមួយឡើយ ។

ពួកគេប្រើប្រាជ្ញាផ្ទាល់របស់គេ ដើម្បីធ្វើការជាមួយនឹង

ធម្មជាតិ ។ យើងត្រូវតែមានសេរីភាព ដើម្បីយល់ដឹង នូវវត្ថុទាំងឡាយ ឲ្យបានសមរម្យ ។

ព្រះពុទ្ធទ្រង់បានចាត់ទុកយើងជាជាមនុស្ស ដែលមានចិត្ត និងសមត្ថភាពខាងគំនិតប្រាជ្ញាស្មារតី។ លោក គ្រីស្នា មូរធី ជាទស្សនវិទូ ដែលគេគោរពយ៉ាងខ្ពង់ខ្ពស់ និងជាអ្នកដែលមិនកាន់សាសនាណាមួយនោះ បានមានប្រសាសន៍ថា ជនណាដែលមិនដឹង ពីរបៀបគិតហើយខ្ចីគំនិតពីអ្នកដទៃ ដូច្នេះគេហៅអ្នកនោះថា ជាមនុស្សថ្នាក់ទី ២ ។

ជនទាំងឡាយណាដែលមានចិត្ត ត្រូវតែគិត និងព្យាយាមយល់នូវរឿងរ៉ាវទាំងឡាយដោយវិចារណញ្ញាណ ដោយមិនចាំបាច់ពឹងពាក់លើអព្ភូតហេតុនានា និងជំនឿទាំងងងឹតងងល់នោះឡើយ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានមានព្រះបំណង ត្រួសត្រាយផ្លូវសម្រាប់យើងដើម្បីគិត ហើយតាមរយៈការយល់ដឹងនេះ យើងគង់រកឃើញនូវអ្វីត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ ។

ព្រះអង្គមានព្រះបំណង បង្រៀនយើងឲ្យចេះពីរបៀបគិត និងរបៀបយល់ដឹង តាមរយៈការពិសោធ និងរបៀបធ្វើការនោះៗ ។ គឺព្រះអង្គចង់ឲ្យយើងសិក្សាអនុវត្ត និងធ្វើពិសោធន៍

មើលសិន ទ្រង់មិនបានធ្វើឲ្យយើង ជឿអ្វីៗទាំងងងឹតងងល់នោះទេ ។

## មនុស្ស និងសាសនា

នៅពេលដែលមនុស្ស បានគិតដល់ជីវិតរបស់គេជាលើកដំបូង ពេលនោះមិនទាន់មានសាសនានៅឡើយទេ ។ តាមរយៈបទពិសោធន៍ ពួកគេបានដឹងនូវគ្រោះថ្នាក់ នៃសភាពឃោរឃៅ សេចក្តីក្រោធ និងសេចក្តីឈ្នានីសជាដើម ទាំងនេះ ជាចរិតពីធម្មជាតិ ។

ម្យ៉ាងវិញទៀត គេក៏បានដឹងនូវសារសំខាន់ នៃមេត្តាករុណា សប្បុរសធម៌ ការព្រមព្រៀងគ្នា ខន្តី និងការអត់អោនអធ្យាស្រ័យផងដែរ ។ ចរិតលក្ខណៈទាំងនេះ មិនមែនអាទិទេពឬបុគ្គលមានឫទ្ធិណាមួយជាអ្នកផ្តល់ឲ្យនោះទេ។ ប៉ុន្តែគឺជាផលពីធម្មជាតិ នៃឥទ្ធិពលទៅវិញទៅមកនៃវិញ្ញាណទាំងប្រាំរបស់យើង ។ នៅពេលដែលវិញ្ញាណទាំងនេះ ធ្វើអន្តរកម្មរវាងគ្នាទៅវិញទៅមក វិញ្ញាណទី ៦ គឺចិត្ត ក៏បានកើតឡើង ។ ពេលនោះតាមរយៈបទពិសោធន៍ បុព្វបុរសរបស់យើង ក៏បានយល់នូវគ្រោះថ្នាក់ នៃទង្វើអវិជ្ជមាន និងសារៈសំខាន់នៃទង្វើវិជ្ជមាន ។

ពួកគេបានអភិវឌ្ឍទ្រឹស្តីមនុស្សនិយមជំនួសឲ្យសាសនា គឺការរស់នៅក្នុងភាពចុះសម្រុងគ្នា ជាមួយនឹងមិត្រភក្តិរបស់គេ ប្រកបដោយបញ្ញា សហប្រតិបត្តិការ និងអនុវត្តនូវការអត់អោនអធ្យាស្រ័យដល់គ្នា ។ ហើយនិងជៀសវាងការធ្វើអំពើអាក្រក់ អំពើអសីលធម៌ និងរឿងរ៉ាវសាហាវយង់ឃ្នងនានា ។ នេះគឺពាក្យថា "មនុស្ស" ។

ហេតុនេះហើយ ទើបគេបានអធិប្បាយពន្យល់នូវទស្សនៈសួគ៌ និងនរក ដោយពង្រីកនូវបទពិសោធន៍បច្ចុប្បន្នរបស់គេខាងផ្នែកសន្តិភាព សេចក្តីសុខ និងសេចក្តីទុក្ខ មិនចេះចប់មិនចេះហើយនោះ ។ នៅពេលពួកគេបានអភិវឌ្ឍ នូវគុណធម៌ទាំងនេះ យោងទៅតាមចំណេះដឹងរបស់គេ នាពេលនោះហើយ ពួកគេបានដឹងថាមានញាណសក្តិសាកលមួយ ដែលអាចដឹងនូវបញ្ហាជីវិតគ្រប់យ៉ាង បានដោយហ្មត់ចត់ ។

ឯអ្នកមានព្យាយាមសម្រេចបានចំណេះដឹង ដល់កម្រិតនេះនៅប្រទេសឥណ្ឌាសម័យបុរាណ មុនសម័យពុទ្ធកាលគេបានឲ្យឈ្មោះនោះថា សក្តិ **(Shakti)** ហើយគេបានចាប់ផ្តើមគោរពសក្តិនេះតរៀងមក ។ ដោយសារតែមានរឿងជាប់ទាក់ទងដូច្នេះហើយ ទើបគេហៅអ្នកទាំងនោះថា អ្នកគោរពបូជាសក្តិ ។

បន្ទាប់ពីការគោរពសក្តិ អស់អំឡុងពេលដ៏យូរមក ពួកគេក៏បានលើកតម្កើងជាតួអង្គពុទ្ធិសាកល ហើយបានគោរពបូជាដូចជា "អាទិទេព" មួយអង្គ ។

ទស្សនវិទូសញ្ជាតិអាមេរិកដ៏ល្បីល្បាញម្នាក់ គឺលោកសាស្ត្រាចារ្យ ហ្វាយ ហែត បានអះអាងថា ដំបូងមនុស្សជាអ្នកបង្កើតអាទិទេព ហើយក្រោយមក ទើបអាទិទេពបង្កើតមនុស្សវិញ ។ ដំបូង ទស្សនៈអាទិទេពបានត្រូវបង្កើតឡើង នៅក្នុងចិត្តរបស់មនុស្សហ្នឹងឯង មិនមានអ្វីផ្សេងពីនេះឡើយ។ ក្រោយមកការអភិវឌ្ឍក៏ចេះតែមានច្រើនឡើងៗ រហូតបានធ្វើបដិរូបកម្មឡើង រួចហើយផ្តល់នូវបដិរូបកម្មនោះ ដល់បុគ្គលិកកម្មរបស់មនុស្សវិញ ។

ដូច្នេះហើយ បានជាតួអង្គអាទិទេពរបស់សាសនាជាច្រើនត្រូវបានគេចាត់ទុកថា ជាតួអង្គដូចមនុស្សសាមញ្ញ ព្រោះនៅមានការប្រណែនឈ្នានីស គំនុំ ការបំផ្លាញ និងងាយធ្លាក់ទៅរកផ្លូវកាមគុណ ។ ទោះបីជាអាទិទេពទាំងនោះ ត្រូវបានបញ្ញត្តថា ដូចជាឪពុកចេះអាណិតស្រលាញ់ ចេះលើកលែងទោសនិងត្រឹមត្រូវក៏ដោយ ។

# ចិត្តមនុស្សស្មានមិនត្រូវ

ព្រះសង្ឃ ៣ អង្គ បាននិមន្តចេញទៅព្រៃ ដើម្បីធ្វើកម្មដ្ឋាន ហើយបានព្រមព្រៀងគ្នាថា មិននិយាយរកគ្នា ស្ថិតក្រោមបរិយាកាសមួយ រហូតដល់បានសម្រេចនូវការចម្រើនខាងប្រាជ្ញាស្មារតី ឬភាពជាអ្នកសប្បុរស ។ បន្ទាប់មក ព្រះសង្ឃ ៣ អង្គនោះក៏បានចាប់ផ្តើមធ្វើភាវនា ។

ក្នុងខណៈពេលដែលលោកកំពុងធ្វើភាវនា ស្រាប់តែព្រះសង្ឃមួយអង្គនិយាយថា លោកភ្លេចបិទទ្វារបន្ទប់របស់លោកហើយ មិនដឹងជាមានអ្វីកើតឡើងនៅទីនោះទេ ។

ពេលនោះ ព្រះសង្ឃមួយអង្គទៀតក៏បានមានថេរដីកាថា "យើងបានព្រមព្រៀងគ្នាថា មិននិយាយរកគ្នាទេ ចុះដូចម្តេចបានជាលោកនិយាយដូច្នេះ" ។

ព្រះសង្ឃអង្គទី ៣ ក៏បាននិយាយដោយអំនួតថា "តាមពិតខ្ញុំមិនដែលនិយាយរឿងរ៉ាវតូចតាចដូចនេះទេ ។ ហេតុអ្វីបានជាលោកទាំងពីរ មិនអាចនៅស្ងៀមដូចជាខ្ញុំ?"

នេះជាធម្មជាតិនៃចរិតរបស់មនុស្ស។ មិនដឹងថាមូលហេតុអ្វីយើងបានសម្រេចចិត្តត្រូវធ្វើការងារហើយ ក្រោយមកយើងបែរជាត្រលប់មករកចរិត និងទម្លាប់ពីធម្មជាតិទៅវិញ ។

ហេតុដូច្នេះហើយ បានជាលំបាកសម្រេចចិត្តរបស់ខ្លួន ដើម្បីធ្វើ ឬមិនត្រូវធ្វើ នូវវត្ថុដ៏ជាក់លាក់ណាមួយនោះ ។

ការបង្រៀនប្រការដែលល្អ យើងត្រូវបញ្ជូនកូនៗរបស់យើង ឲ្យទៅរៀននៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ និងថែមទាំងឲ្យពួកគេទៅរៀននៅសាលាឯកជនទៀតផង ។ ប៉ុន្តែពួកគេអាចរៀនយកនូវរឿងរ៉ាវ ដែលអាក្រក់ទាំងអស់បានយ៉ាងងាយ ដោយមិនបាច់មានការបង្ហាត់បង្រៀន ឬក៏ទៅសាលារៀន ដែលឥតបង់ថ្លៃហ្នឹងតែម្តង!

បច្ចុប្បន្ន នៅក្នុងសង្គមទំនើប ប្រជាជនជួបប្រទះនូវបញ្ហាលំបាកជាច្រើន ក្នុងការរក្សាសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ប៉ុន្តែធម្មជាតិនៃសត្វរបស់ពួកគេ បែរជាងាយស្រួលជាស់តឿនក្រើនរំលឹកទៅវិញ ។ ទាំងរបៀបឬកពារដែលមនុស្សយើងប្រព្រឹត្តធ្វើសព្វថ្ងៃ ទាំងរបៀបដែលគេស្លៀកពាក់ និងអ្វីដែលពួកគេធ្វើបានធ្វើឲ្យពួកគេភ្លេចនូវតម្លៃ និងវិន័យសីលធម៌ របស់មនុស្សខ្លួនឯង ។

នៅក្នុងអតីតកាល មនុស្សបានថែរក្សានូវសេចក្តីថ្លៃថ្នូររបស់ខ្លួន ដោយអនុវត្តតាមវប្បធម៌របស់ខ្លួន និងរបៀបរស់នៅគឺគេប្រកាន់យកសន្តិភាព ការបុះសម្រុងគ្នា ការសាមគ្គី និង

ការយោគយល់គ្នា ។

បច្ចុប្បន្ន ពេលយើងអានកាសែត ព័ត៌មានប្រចាំថ្ងៃ យើងអាចឃើញចំណុចព័ត៌មានជិត ៩០% ដែលគួរឲ្យខ្មាសអៀន យោរយៅអាក្រក់ អសីលធម៌ មានអំពើហិង្សា និងការកាប់សម្លាប់ បង្ករឈាមគ្នា ។ ឧទាហរណ៍ៈ ក្មេងអាយុតែ ៦ ឆ្នាំ សោះហ៊ានបាញ់សម្លាប់ សិស្សនៅក្នុងសាលារៀនទៅហើយ ។ ពួកគេបានរៀនយកនូវរឿងរ៉ាវដ៏អាក្រក់ទាំងនេះ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ជាពិសេសទូរទស្សន៍ ។

ក្មេងៗចូលចិត្តយកតម្រាប់តាម នូវអ្វីដែលមនុស្សចាស់ធ្វើ ជាពិសេសគឺអ្វីដែលពួកគេឃើញ នៅតាមកញ្ចក់ទូរទស្សន៍នេះឯង ។ ប៉ុន្តែយើងត្រូវចេះបែងចែករឿងនេះឲ្យបានត្រឹមត្រូវ។

ព័ត៌មានដែលយើងទទួលបាន ពីគ្រឿងផ្សព្វផ្សាយដូចជា វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្ដីជាដើម វាមានប្រយោជន៍ច្រើនយ៉ាងណាស់សម្រាប់យើង ព្រោះវាបានបង្ហាញយើងនូវចំណុចដែលយើងអាចស្រូបយកបានដ៏ប្រសើរបំផុតពីបញ្ហាជីវិតរបស់យើង ។ ក៏ប៉ុន្តែមនុស្សមិនហ្មត់ចត់ គ្មានសាសនា រមែងកេងប្រវ័ញ្ចយកផលប្រយោជន៍ ពីចំណុចខ្សោយរបស់យើង ហើយលើកតម្កើង នូវវប្បធម៌ពាលាអាវ៉ាសែរបស់យើងទៅវិញ ។

ចំណុចត្រង់ហ្នឹងហើយ ដែលយើងត្រូវប្រយុទ្ធប្រឆាំងនោះ មិនមែនប្រឆាំងនឹងគ្រឿងផ្សាយព័ត៌មាននោះទេ ។

## សេរីភាព ក្នុងការជ្រើសរើស

គំនិតយល់ខុស និងគំនិតភ្ញាក់ផ្អើលជាទូទៅរមែងកើតមាននៅក្នុងចំណោមពុទ្ធសាសនិកទាំងឡាយ ។ នៅក្នុងនោះឪពុកម្ដាយ មិនមានទំនួលខុសត្រូវ និងមិនបានធ្វើឲ្យជាក់ច្បាស់ថាបុត្រធីតារបស់ពួកគេ រៀនយកនូវឱវាទ ឬព្រះធម៌ដ៏ប្រសើរទាំងនៅជាពុទ្ធសាសនិកផងទេ ។

ជារឿយៗ ពួកគេប្រកាសដោយមោទនភាពថា គេបានផ្ដល់សិទ្ធិសេរីភាព ដល់បុត្រធីតារបស់គេ ដើម្បីជ្រើសរើសសាសនា ដោយខ្លួនគេផ្ទាល់ ទោះបីជាពួកគេនៅក្មេងក៏ដោយ ។ នេះជាឥរិយាបថមួយដែលមានកំហុសធ្ងន់យ៉ាងធ្ងន់ធ្ងរ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្ដែង សង្កត់ធ្ងន់ទៅលើឫសគល់នៃអំពើបាបមួយ ក្នុងចំណោមអំពើបាបទាំងឡាយ ដែលមាននៅក្នុងមិច្ឆាទិដ្ឋិ ។

គួរឲ្យកត់សំគាល់ផងដែរថា ប្រសិនបើបុគ្គលជាអ្នកទទួលខុសត្រូវ ដូចជាឪពុកម្ដាយ ទុកឲ្យអ្នកដទៃធ្លាក់ទៅក្នុងមិច្ឆាទិដ្ឋិ

ឪពុក ឬម្ដាយនោះ គឺខុសប្រាសចាកគន្លងសីលធម៌ ហើយត្រូវបង់ខាតជាច្រើន ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសយ៉ាងច្បាស់ថា ឪពុកម្ដាយជាអ្នកមានទំនួលខុសត្រូវដ៏ធ្ងន់ចំពោះបុត្រធីតារបស់ខ្លួន ។ ដោយឃើញថា បុត្រធីតាទាំងនោះ មិនត្រូវបានឲ្យដឹកនាំ ទៅរកផ្លូវខុសឃ្លាតចាកពីផ្លូវត្រូវ និងមិនឲ្យបណ្ដុះបណ្ដាលពួកគេទៅរករបៀបមនុស្សប្រាស់នោះទេ ។

ឪពុកម្ដាយទាំងឡាយ រមែងគិតខុសថា ការផ្ដល់សេរីភាពខាងការជ្រើសរើស មានន័យថាបានអើពើ ចំពោះទំនួលខុសត្រូវខាងស្មារតីរបស់ខ្លួន ចំពោះបុត្រធីតាទាំងនោះហើយ ។ ពួកគាត់ថែមទាំងអាចត្រូវបានគេចោទប្រកាន់ ពីគោលបំណងស្វែងរកលេសចំពោះកោសជ្ជភាពរបស់ខ្លួនទៀតផង។បើយោងទៅតាមផ្លូវធម៌ ភារកិច្ចនៃការចិញ្ចឹមបីបាច់អប់រំកូន មិនមែនជារឿយងាយស្រួលទេ គឺតម្រូវឲ្យមានការបូជាតបគុណវិញ ។

ពួកគេលាងជម្រះដៃរបស់ពួកគេ ហើយលាក់បាំងនូវគំនិតខុស នៅខាងក្រោយហើយថា ព្រះពុទ្ធសាសនាបណ្ដោយឲ្យមនុស្សជឿតាមជំនឿគ្រប់យ៉ាង ដោយខ្វះវិចារណញ្ញាណ ។

ក្មេងដែលមិនទាន់ពេញវ័យ និងជាពិសេស គឺក្មេងពេញ

វ័យហើយហ្នឹងតែម្ដង គឺងាយស្រួលត្រូវបានគេធ្វើឲ្យទោរទន់ទៅរកការសន្យាដែលគ្មានតម្លៃ ។

យើងជាឪពុកម្ដាយ ត្រូវតែការពារទប់ទល់បញ្ហានេះ ដោយការណែនាំប្រាប់ផ្លូវ ឬដាស់ចិត្តពួកគេ ដើម្បីស្វែងរកសេចក្ដីសុខ លុះអវសាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានចំណាយពេល ៤៥ ព្រះវស្សា ដើម្បីរាវរកនូវមិច្ឆាទិដ្ឋិនេះ នៅក្នុងប្រព័ន្ធសាសនានានា មិនតិចជាង ៦២ សាសនាទេ ។ នៅក្នុងពេលណាៗក៏ដោយ ព្រះពុទ្ធមិនដែលត្រាស់ថា រឿងនេះ "ត្រឹមត្រូវ" ត្រូវកាន់តាមជំនឿបែបនេះ ឬបែបនោះទេ ។ អ្វីដែលព្រះពុទ្ធទ្រង់បានត្រាស់នោះ គឺខុសទាំងស្រុង ទៅនឹងការល្បួងចិត្ត ដែលគ្មានទោសកំហុសឲ្យធ្លាក់ទៅក្នុងជំនឿខុស ដែលមានតែការសន្យា តែគេមិនបានឲ្យតម្លៃតាមរយៈការស៊ើបអង្កេតនោះឯង ។

ពិតណាស់ ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនអនុញ្ញាតឲ្យសាវ័ករបស់ព្រះអង្គដុត ឬជ្រមុជទឹកនរណាម្នាក់ ដែលមិនបានជឿតាមព្រះអង្គ ឲ្យស្លាប់នោះទេ ។

សេរីភាពនេះ គឺខុសគ្នាពីពាក្យដែលថា ព្រះពុទ្ធបានបណ្ដោយឲ្យបុគ្គលគ្រប់រូបធ្លាក់ទៅនរក តាមគន្លងរបស់ព្រះ

អង្គទៅវិញ ។

ព្រះធម៌របស់ព្រះពុទ្ធ បានបង្ហាញយ៉ាងច្បាស់ ពីបុគ្គលដែលមានជំនឿខុស ហើយចេះតែបន្តមានទុក្ខក្នុងវដ្តសង្សារអស់រយៈពេលច្រើនហួសគណនា ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងដែរថា យើងមានសំណាងណាស់ ដែលកើតមកជាមនុស្ស អាចរៀននូវព្រះធម៌ ហើយដើរតាមផ្លូវ ដែលនាំទៅរកការសង្គ្រោះ ដល់ទីបំផុតបាន ។

ក្មេងៗដែលយើងបង្កើតមក យើងសង្ឃឹមថាត្រូវបានផ្តល់ឱកាសគ្រប់យ៉ាង ដើម្បីបានក្លាយខ្លួនទៅជាពុទ្ធសាសនិកដ៏ល្អ និងមានបញ្ញា ។ ប្រសិនបើយើងមិនបានចាក់យកឱកាសដ៏កម្រនេះ ដើម្បីទាញយកញផលប្រយោជន៍ពីព្រះធម៌ និងបណ្តុះនិស្ស័យខាងព្រះធម៌នេះ ទៅដល់ក្មេងៗ ជំនាន់ក្រោយរបស់យើងទេ យើងនឹងបរាជ័យក្នុងទំនួលខុសត្រូវរបស់យើង ប្រៀបដូចជាសត្វស្វា ដែលបោះចោលនូវត្បូងពេជ្រ ព្រោះហេតុវាមិនបានដឹងពីតម្លៃនៃដុំពេជ្រនោះ ដូច្នោះឯង ។

ដូចដែលខ្ញុំបានពន្យល់ពីខាងដើមហើយថា សាសនាមានសច្ចៈនេះ បានក្លាយជាផ្នែកមួយដ៏សំខាន់ នៃវប្បធម៌របស់យើង នៅក្នុងអាស៊ី ហើយបានសូនយកនូវព្រលឹងរបស់យើង

តាមវិធីដ៏ល្អិតល្អន់ ។ ប្រសិនបើយើងខ្លួនឯង មិនយល់នូវវប្បធម៌ដ៏ស្រស់បំព្រងនេះទេ ព្រោះហេតុយើងខ្ជិលរៀនសូត្រ រួចហើយចាប់យក នូវវប្បធម៌ធើតធាយថ្មីស្រឡាង ប៉ុន្តែមិនល្អ គ្មានខ្លឹមសារទេនោះ យើងនឹងបង់ថ្លៃ ក្នុងការបាត់បង់បុត្រធីតារបស់យើង និងប្រយោជន៍នៃសុខុមាលភាពរបស់យើង ។

យើងអាចសួរខ្លួនឯងផងដែរថា ហេតុអ្វីយើងកើតមកជាពុទ្ធសាសនិក ប្រសិនបើបំណងដើម ត្រូវធ្វើឲ្យយើងផ្លាស់ប្តូរចិត្តរបស់យើងអ៊ីចឹង ។ មិនមានចម្លើយណាមួយ គួសបញ្ជាក់ថា នរណាម្នាក់ទទួលសារភាពនូវកំហុស ក្នុងការធ្វើយើងឲ្យកើតមក ជាពុទ្ធសាសនិកទេ មែនឬ?

មែនហើយ រឿងនេះពិតជាមិនត្រូវបំភ័យ និងគម្រាមកំហែងលោកអ្នក ដោយនរកនិងការដាក់បណ្តាសានោះទេ ប្រសិនបើលោកអ្នកហ៊ានប្រើចិត្ត របស់ខ្លួនជំទាស់នោះ ។ ជាក់ស្តែង យើងមិនបង្កើតសេចក្តីភ័យខ្លាច នៅក្នុងខ្លួនរបស់លោកអ្នក ដោយនិយាយថា ប្រសិនបើបុត្រធីតារបស់លោកអ្នកស្តាប់ធម៌របស់សាសនាដទៃ ឬបរិភោគអាហារក្នុងពិធីបុណ្យគេ ឬប៉ះពាល់ដល់គម្ពីរធម៌របស់គេ បុត្រធីតាទាំងនោះ នឹងធ្លាក់ទៅនរកអស់មួយអនន្ត ដូច្នោះទេ!

ពុទ្ធសាសនិកទាំងឡាយ ត្រូវបានអនុញ្ញាតឲ្យរកនូវសច្ចៈភាព នៅក្នុងសាសនាដទៃដោយសេរី ។ ទេ! នេះគឺគ្រាន់តែជាការលោតត្រដាងចំពោះលោកអ្នកទុកជាមុននូវភាពពិតនៃជីវិត។

ជាឪពុកម្តាយគេ លោកអ្នកត្រូវតែរៀននូវព្រះធម៌ និងយល់នូវវប្បធម៌របស់ខ្លួន រួចហើយត្រូវធ្វើឲ្យជាក់ច្បាស់ថែមទៀត ។ ឯកូនចៅរបស់យើង ក៏ត្រូវបង្រៀនឲ្យបានពេញលេញអំពីវប្បធម៌នោះដែរ ។

ប្រសិនបើ បន្ទាប់ពីលោកអ្នក បានបំពេញនូវភារកិច្ចរបស់លោកអ្នករួចហើយ កូនចៅក៏បានជ្រើសរើសរកបរិយា-កាសសង្គមងាយស្រួល នៅក្នុងសាសនាដទៃ ។ ដល់ពេលនោះ ចាំទុកបណ្តោយតាមចិត្ត របស់ពួកគេចុះ ។ នេះហើយជាអត្ថន័យ នៃពាក្យថា "សេរីភាព" នោះ ។

តើពាក្យនេះច្រើនហួសរហូតដល់យល់មិនកើតឬ?

## សាសនា និងអ្នកគិតសេរី

សព្វថ្ងៃនេះ សាសនាប្រើសម្រាប់គ្រាន់តែសូត្រធម៌ គោរពបូជា និងមានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ ។ ប៉ុន្តែ មិនសូវមានសកម្មភាព ខាងការអប់រំបន្ទុះចិត្តគំនិតនោះទេ ។

យើងមិនអាចក្លាយជាអ្នកកាន់សាសនាពិត ដោយគ្រាន់តែសូត្រធម៌ ឬក៏ធ្វើការគោរពបូជាប៉ុណ្ណោះទេ ។ ព្រោះគំនិតដ៏ឃោរឃៅ កាចអាក្រក់ គ្រោះថ្នាក់របស់យើងទាំងអស់គ្នា គ្រប់ដណ្តប់លើចិត្ត របស់យើងជាប្រចាំទៅហើយ ។

ជំនឿខាក់ក្នុងវត្តប្រតិបត្តិ អន្ទុយសូត្រធម៌ម្នាក់ឯង មិនអាចធ្វើចិត្តឲ្យបរិសុទ្ធបានទេ ។

នៅក្នុងលោកនេះ មានអ្នកគិតសេរីជាច្រើន ដែលមិនជឿលើអាទិទេព សួគ៌ នរក កម្មផល បដិសន្ធិ និងអត្តា (តួខ្លួន) ឬអាត្ម័ននោះ ។

បញ្ហាទាំងនេះហើយគឺជាកត្តាចោទរបស់សាសនាទាំងឡាយ ហើយជនទាំងនេះមិនជឿលើសាសនាទាំងនោះទៀត ។

លោកអាស៊័រ ស៊ី ខ្លាក, ខាលសាហ្គែន, ហ្គ. ប៊ើន ណាតស, គ្រីស្នា មួរធី និងលោក ប៊ើតត្រេនន៍ រុស់សែល ជាដើម សូមរាប់ឈ្មោះ តែពីរ បីនាក់ប៉ុណ្ណោះ ។ អ្នកទាំងនេះសុទ្ធតែបដិសេធចោល នូវសាសនាជាប្រពៃណី ។ ប៉ុន្តែ ពួកគេជាមនុស្សល្អ ព្រោះគេមិនបានធ្វើឫកពារ ដូចមនុស្សឃោរឃៅទាំងពួងទេ ។

តាមពិតទៅ ជនមួយចំនួនដែលមិនកាន់សាសនា គឺមាន

លក្ខណៈប្រសើរច្រើនជាងជន ដែលប្រកាសខ្លួន ពាក់ស្លាកសាសនានានាទៅទៀត ។ ដោយដឹងថា រឿងរ៉ាវណាមួយអាក្រក់ គេក៏ជៀសវាងអំពើនោះ ។

ដោយដឹងនូវអានុភាពនៃមេត្តា គេក៏ខំចម្រើន នូវសេចក្តីករុណា សាមគ្គី និងមុទិតា និងខិតខំបំពេញនូវគុណធម៌ផ្សេងៗទៀត ដើម្បីរំដោះទុក្ខរបស់មិត្តភក្តិ ដោយមិនរំពឹងគិតចង់បានវង្វាន់ពីអាទិទេព មិនចង់បានបដិសន្ធិដ៏ប្រសើរ បន្ទាប់ពីចុតិ ។ ប៉ុន្តែ ពួកគេជ្រាបតាមរយៈយល់ដឹងដោយបញ្ញា អំពីសាមគ្គីភាពជាសារវន្ត របស់មនុស្សលោកទាំងអស់ ។

យើងអាចនិយាយបានថា ពួកគេមានចិត្តជាអ្នកកាន់សាសនាច្រើនជាង ហើយពួកគេលើកតម្កើងគោលការណ៍ទាំងឡាយ របស់សាសនាទៀតផង ថ្វីត្បិតតែពួកគេមិនបានកាន់ស្លាកសាសនាក៏ដោយ ។

## បុគ្គលដូចម្តេច ទើបឈ្មោះថាបាននៅជិតព្រះពុទ្ធ?

ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនមានបំណងបង្កើតសាសនា គ្រាន់តែសម្រាប់បុគ្គលមកធ្វើសក្ការបូជា និងសូត្រធម៌ប៉ុណ្ណោះទេ ។

ព្រះសម្មាសម្ពុទ្ធបានទ្រង់ថា “សាវ័កទាំងឡាយណា ដែល

ដើរតាមតថាគតដោយកាន់ដៃ ឬកាន់ចីពររបស់តថាគត មិនឲ្យឈ្មោះថា នៅជិតនឹងតថាគតទេ ប្រសិនបើចិត្តរបស់គេមិនបរិសុទ្ធ" ។ សាវ័កទាំងឡាយ នៅឆ្ងាយពីតថាគតរាប់យោជន៍ បើទោះជាមិនឃើញតថាគតក៏ដោយ តែប្រសិនបើគេធ្វើតាមដំបូន្មានរបស់តថាគត និងរក្សានូវភាពបរិសុទ្ធនៅក្នុងចិត្តរបស់ខ្លួន សាវ័កនោះទើបឈ្មោះថា នៅជិតនឹងតថាគត ។ នេះគឺជាឥរិយាបថ របស់ព្រះសម្មាសម្ពុទ្ធ ។

ព្រះអង្គទ្រង់មិនបានប្រាថ្នាចង់បន្ទាបបុគ្គលណាមួយ ដោយបង្កើតនូវសេចក្ដីភ័យខ្លាច ឬដោយការទាមទារឲ្យមានការបុះចាញ់ទាំងស្រុង ចំពោះឫទ្ធិអំណាច របស់ព្រះអង្គឡើយ ។

ព្រះអង្គទ្រង់បានទូន្មានយើង ឲ្យគោរពនូវបុគ្គលដែលគួរគោរព ដោយមិនចាំបាច់គិតដល់សាសនា ឬជាតិសាសន៍របស់គេទេ និងថែមទាំងឲ្យយើងគោរព ដល់បុគ្គលដែលមិនបានប្រកាសខ្លួនថាជាសមាជិក របស់សាសនាណាមួយផងដែរ ។

ប្រសិនបើយើងគិតថា ពួកគេគួរឲ្យគោរព យើងអាចគោរពពួកគេបាន ។

ចំណុចត្រង់នេះជាចំណុច ដែលត្រូវហាមយើង មិនឲ្យព្យាយាមបញ្ចុះបញ្ចូលអ្នកកាន់សាសនាណាមួយ ដោយការ

គម្រាមកំហែង និងមិនឲ្យប្រកាន់ភេទ ជាតិ សាសន៍ របស់អ្នកដទៃ ។

## ការប្រកាន់ភេទ និងការធ្វើទារុណកម្ម

យើងដឹងតាមព័ត៌មាន ដែលយើងអានប្រចាំថ្ងៃថា ការប្រកាន់វណ្ណៈភាគច្រើន គឺស្ត្រីភេទហ្នឹងឯង ។ មិនថាឡើយតែនៅផ្ទះទេ ទោះជានៅកន្លែងធ្វើការក្តី ស្ត្រីទាំងនោះត្រូវបានគេរើសអើង យ៉ាងអាក្រក់បំផុត ។ សូម្បីនៅសាសនាក៏ដោយ ស្ត្រីទាំងឡាយបានប្រយុទ្ធទាមទារសិទ្ធិយ៉ាងលំបាក ដើម្បីឲ្យគេគោរពក្នុងនាមជាមនុស្សដូចគ្នា ។

តួយ៉ាង ស្ត្រីទាំងឡាយត្រូវបានហាមឃាត់ មិនឲ្យចូលទៅទីកន្លែងគោរពបូជា ក្នុងសាសនាជាច្រើន ។ ព្រះសម្មាសម្ពុទ្ធ ជាសាស្ត្រាចារ្យ ខាងសាសនាដំបូងបង្អស់ ដែលបានបើកទ្វារសម្រាប់ស្ត្រី ឲ្យចូលទៅក្នុងជំនុំសង្ឃ ឲ្យធ្វើជាដូនជីពេញលក្ខណៈ ដើម្បីអនុវត្តការកិច្ចខាងសាសនា ។

ត្រង់ហ្នឹង យើងអាចយល់នូវអ្វីដែលជាសេរីភាព ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានឲ្យដល់មនុស្សជាតិ ដោយមិនគិតពីភេទ ជាតិ ឬសាសន៍ នោះទេ ។

យើងកាន់សាសនារបស់យើង តាមរយៈបញ្ញាយល់ដឹងពីធម្មជាតិពិតវត្ថុគ្រប់យ៉ាងទាំងអស់ ។

ពុទ្ធសាសនាថែមទាំងមិនឲ្យប្រកាន់ នូវអ្វីដែលគេហៅថាអ្នកទោស ។ ព្រះពុទ្ធសាសនាបានស្គាល់ ពីមនុស្សទោសយ៉ាងច្បាស់ថា យើងមិនអាចផ្លាស់ប្តូរចិត្តរបស់គេបានទេ ។ ដើម្បីផ្លាស់ប្តូរចរិតមនុស្សកាច ទណ្ឌកម្មមិនមែនជាដំណោះស្រាយឡើយ ។

ដូចសត្វដែលបង្វឹកសម្រាប់លេងសៀក ការឃុំឃាំងនៅក្នុងទ្រុង ឲ្យនៅស្ងៀម ព្រោះហេតុនោះសត្វទាំងឡាយ មិនមានអំណាចធ្វើអ្វីបានទេ ប៉ុន្តែនៅពេលដែលវាមានសិទ្ធិសេរីភាពឡើងវិញ វានឹងវិលត្រលប់ទៅរករបៀបជីវិតធម្មតាវិញដដែល ។ ព្រោះយើងមិនមានបំណងធ្វើឲ្យវាផ្លាស់ប្តូរចិត្តរបស់វាឡើយ ។

វិធីសាស្ត្ររបស់ព្រះពុទ្ធ ក្នុងការបញ្ចុះបញ្ចូលឧក្រិដ្ឋជន គឺត្រូវអប់រំពួកគេ ឲ្យធ្វើការផ្លាស់ប្តូរចិត្ត នេះទើបជាទង្វើ មិនមែនធ្វើដោយដាក់ទណ្ឌកម្មទេ ប៉ុន្តែដោយការអប់រំចិត្តនោះ ឲ្យកាន់យកនូវវិន័យសីលធម៌ទៅវិញ ។ យើងដឹងថា យើងទាំងអស់គ្នាមានកំហុស ។ យើងមិនគួរព្យាយាមមើលរំលងបញ្ហា

ដោយនិយាយថា គ្មានអ្វីខុសនោះទេ ។

បុគ្គលដែលកាន់យកនូវសិក្ខាបទទាំងឡាយ រមែងសារភាពថាខ្លួនគេ ស្ថិតនៅក្រោមការមានកំហុសជានិច្ច ។ ម្ល៉ោះហើយគេក៏អប់រំខ្លួនគេ មិនឲ្យធ្វើនូវអំពើអាក្រក់បែបនេះជាថ្មីទៀតទេ។ ហ្នឹងហើយជាអត្ថន័យពិត នៃសិក្ខាបទ ។ នេះគឺជាវិធីសាស្ត្រដែលបង្ហាញដោយព្រះពុទ្ធ គឺមិនឲ្យមានការធ្វើទារុណកម្មទេ ។

## ដាក់ទណ្ឌកម្មចិត្ត

មួយវិញទៀត ដោយបានឃើញថា បុគ្គលមួយចំនួនធ្វើទារុណកម្មរាងកាយរបស់គេ ចំពោះទង្វើខុសរបស់ខ្លួនជាដើម។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ថា រាងកាយមិនមែនជាអ្នកទទួលខុសត្រូវចំពោះកំហុស ដែលបុគ្គលប្រព្រឹត្តធ្វើនោះទេ ។ កាយមិនអាចធ្វើអ្វីបានទេ ចិត្តទេដែលប្រើកាយជាឧបករណ៍ដើម្បីបាននូវអ្វីៗ ដែលវាចង់បាននោះ ។

(គោទេ ជាអ្នកអូសទាញរទេះ ឬនង្គ័ល ឯរទេះ ឬនង្គ័លមិនដែលចេះអូសទាញគោឡើយ) ។

ព្រះពុទ្ធទ្រង់បានត្រាស់ថា “ប្រសិនបើយើងចង់ដាក់ទណ្ឌកម្មអ្វីមួយ ក៏ដាក់ចុះ តែយើងត្រូវដាក់ទណ្ឌកម្មចិត្តរបស់យើង

មិនត្រូវដាក់ទោសលើរាងកាយទេ” ។ តើយើងអាចដាក់ទណ្ឌ-កម្មលើចិត្តយ៉ាងដូចម្ដេច?

នៅពេលយើងមានសេចក្ដីច្រណែនឈ្នានីស ហើយយើងដឹងថា ការច្រណែនឈ្នានីសមិនល្អ យើងត្រូវព្យាយាមទប់កុំឲ្យមានសេចក្ដីច្រណែនឈ្នានីសនេះ ។ នៅពេលយើងក្រោធខឹង ហើយយើងដឹងថា សេចក្ដីក្រោធខឹងនេះ អាចបង្កើតឲ្យមានអំពើហិង្សា ការកាប់សម្លាប់គ្នា និងការចលាចលគ្រប់យ៉ាង យើងត្រូវព្យាយាមសង្កត់នូវសេចក្ដីក្រោធនេះ ។

នេះជារបៀបដាក់ទណ្ឌកម្មចិត្ត ដើម្បីអប់រំចិត្ត មិនមែនធ្វើដោយកម្លាំងអាជ្ញាទេ ប៉ុន្តែត្រូវធ្វើតាមរយៈបញ្ញា និងការមិនឲ្យនូវអ្វីៗ ទៅតាមតម្រូវការរបស់ចិត្តហ្នឹងឯង ។

យើងត្រូវតែធ្វើម្ចាស់ការ លើចិត្តរបស់យើង យើងមិនត្រូវបណ្ដោយឲ្យចិត្តគ្រប់គ្រងលើសកម្មភាពរបស់យើងទេ ។

យើងត្រូវតែរក្សា នូវភាពបរិសុទ្ធទុកក្នុងចិត្ត ពុំនោះសោតទេ ទោះជានៅផ្ទះក្ដី នៅក្នុងសង្គមក្ដី ឬនៅកន្លែងដែលយើងធ្វើការក្ដី យើងនឹងបង្កើត ឲ្យមានសេចក្ដីក្រោធខឹង សេចក្ដីច្រណែនឈ្នានីស អមិត្តភាព សេចក្ដីភ័យខ្លាច និងអសន្តិសុខ ដែលមិនត្រឹមតែរំខានដល់ខ្លួនយើងប៉ុណ្ណោះទេ តែថែមទាំង

រំខានដល់អ្នកដទៃផងដែរ ។

យើងហាត់ពត់លត់ដំខ្លួនយើង ដោយការរក្សាសីល ឬសិក្ខាបទនានា ។ ធ្វើដូចនេះគង់ក្លាយទៅជាទម្លាប់បាន ។

ហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ទ្រង់បានចាប់ផ្តើមធ្វើការផ្សព្វផ្សាយសាសនា របស់ព្រះអង្គ ដោយអប់រំសាវកទាំងឡាយ ឲ្យស្ថិតនៅក្នុងសីល រួមមានទាំងច្បាប់ វិន័យ ឬសិក្ខាបទទាំងឡាយផង ។

## សេចក្តីសន្និដ្ឋាន

វាជារឿងលំបាក ដើម្បីនិយាយថា ជនទាំងឡាយអាចរកឃើញនូវសេចក្តីពិតដ៏ក្រៃលែងនៅក្នុងសាសនាដទៃ ដែលថាគេមិនអាចរកឃើញ នៅក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនោះឡើយ ។

## មរតកកំណាព្យ

កូនខ្មែរចេះភាសាបរទេស　　គួរកុំប្រហែសធ្វេសឱ្យសោះ
គួរស្រូបវិជ្ជាសាស្ត្រនោះៗ　　ហើយប្រែចំពោះជាខ្មែរទៅ ។
ដើម្បីឱ្យខ្មែរមានក្បួនច្បាប់　　សំរាប់សិក្សាចេះជ្រាលជ្រៅ
ធ្វើឱ្យជាតិយើងមានសៀវភៅ　　សំបូរគ្រប់ផ្លូវតាមត្រូវការ ។
សៀវភៅក្បួនច្បាប់ជាតិដទៃ　　មានច្រើនក្រាស់ក្រៃគ្រប់តម្រា
ជាតិគេមិនខ្វះក្បួនសិក្សា　　សិល្បវិជ្ជាសម័យថ្មី ។
បើភាសាខ្មែរ ខ្មែរងាយអាន　　មើលឆាប់ស្គាល់យល់សេចក្តី
ហេតុនេះគួរយើងយល់ខំឃ្នាតខ្មី　　សាងក្បួនថ្មីៗជាខ្មែរអើយ ។

(ដកស្រង់ពីសៀវភៅ ណាប៉ូឡេអុងមហារាជា) របស់លោក
សាស្ត្រាចារ្យ ឱម ណាត្រី

ឧបត្ថម្ភបោះពុម្ពដោយ
**អង្គការព្រះធម៌ជំនួយអាស៊ី**
សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ ហាមលក់!
Dhamma Aid Asia
For Free Distribution, Not For Sale!

9 789996 356933